ខែ មីនា ឆ្នាំ 2015

សូមចូលទៅកាន់គេហទំព័រ www.itcity.com.kh ដើម្បីទាញយកទស្សនាវដ្ដីទីក្រុងពត៌មានវិទ្យាដោយឥតគិតថ្លៃ

ទំនាក់ទំនងផ្សាយពាណិជ្ជកម្ម 010 67 67 67 / 018 333337

184

# it MAGAZINE ទស្សនាវដ្ដី ទីក្រុង ពត៌មានវិទ្យា

we live with technology

IT CITY MAGAZINE



## គ្រប់គ្រង Project បានយ៉ាងងាយជាមួយ Project KickStart Pro5

## វិធីសាស្ត្រធំៗ ១០ ដើម្បីការពារពត៌មានអ្នក នៅលើអ៊ីនធើណេត

## ស្វែងយល់លក្ខណៈរបស់

- Asus G751 - Lenovo Yoga 3 pro
- Dell Inspiron Small - Thinkcentre E63z



## GEFORCE GTX 980

ពិសេសល្អបំផុតសម្រាប់លេងហ្គេម



## QNAP TS-651

ផ្ដល់សុវត្ថិភាពជាទីទុកចិត្ត

## របៀបប្រើប្រាស់ desktop បានច្រើន ក្នុងពេលតែមួយក្នុង Windows 10


digital
Computer · Phone · Camera security
យើងផ្តល់នូវ ផលិតផល
ដែលមាន គុណភាពខ្ពស់
សម្រាប់ តម្រូវការរបស់លោកអ្នក
digital
សូមអញ្ជើញមកកាន់ Digital Show Room :
ផ្ទះលេខ ៨ AEo ផ្លូវ ១៥៦ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរស័ព្ទ : 023 555 6 777

Herbal Health

# ថ្នាំបំប៉ន
# ផ្សំឡើងដោយ
# រុក្ខជាតិធម្មជាតិ ១០០%

## Jointcare

មានប្រសិទ្ធិភាពខ្ពស់
ក្នុងការព្យាបាល:

- ✓-រលាកសន្លាក់ឆ្អឹង
- ✓-ជម្ងឺប្រគ្រីវ
- ✓-កាត់បន្ថយការតានតឹង ខ្វល់ខ្វាយក្នុងអារម្មណ៍
- ✓-ការពារជម្ងឺកើតមុន និងរោគរលាកស្បែក
- ✓-រោគសន្លាក់ឆ្អឹងផ្សេងៗ




Herbal Health

ទីស្នាក់ការធំ រាជធានីភ្នំពេញ :
ផ្ទះលេខ 8AE0 ផ្លូវលេខ 156 សង្កាត់វាលវង់
ខណ្ឌ ៧មករា រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ 023 67 68 711 / 088 8651111 / 016 555 889




# អ្នកប្រើប្រាស់បច្ចេកវិទ្យាថ្មីជាច្រើនបានបង្ហាញចំណាប់អារម្មណ៍ពេញចិត្ត ជាមួយនឹងប្រព័ន្ធដំណើរការ Windows 10

តាំងពីមានពត៌មានចចាមអារាមតាំងពីដំបូងរហូតដល់ពេលចេញបង្ហាញជាផ្លូវការអ្នកប្រើប្រាស់បច្ចេកវិទ្យាថ្មីជាច្រើនបានបង្ហាញចំណាប់អារម្មណ៍ពេញចិត្តជាមួយនឹងប្រព័ន្ធដំណើរការ Windows 10។ គម្រោងការដាក់បង្ហាញប្រព័ន្ធដំណើរការថ្មីនេះគេទទួលស្គាល់ជាផ្លូវការទូទាំងសាកលលោក ប៉ុន្តែកម្មវិធីប្រើប្រាស់ដែល Support ជាមួយមិនទាន់មានគ្រប់នៅឡើយ ហើយពេលនេះកម្មវិធីមួយចំនួនត្រូវបានប្រកាសថាមានសមត្ថភាព Support ជាមួយប្រព័ន្ធដំណើរការថ្មីនេះ។

ក្រុមហ៊ុន Microsoft ទើបតែបង្ហាញគម្រោងប្រកាសប្រព័ន្ធដំណើរការកម្មវិធី Window Phone របស់ខ្លួនបានពីរសប្តាហ៍ តែពេលនេះមានពត៌មានថ្មីបង្ហើបពីកម្មវិធីដែលមានសមត្ថភាព Support ដំបូងគេមួយចំនួន។ ក្នុងដំណាក់កាលដែលគេកំពុងត្រួតពិនិត្យ និងអភិវឌ្ឍន៍លើប្រព័ន្ធដំណើរការ Windows 10 ក៏មានកម្មវិធីមួយចំនួនដូចជា Word Excel និង Power-Point សម្រាប់អ្នកប្រើ PC កុំព្យូទ័រយួរដៃឧបករណ៍ Tablet ដែល Update ប្រើ Windows 10 Technical Preview ។




ក្រុមហ៊ុនMicrosoft បានលើកឡើងថា មួយវិញទៀត កម្មវិធី Outlook និង OneNote អាចរចនាមកប៉ះបញ្ហាបានសម្រាប់កម្មវិធីទូរស័ព្ទ។ ក្រុមហ៊ុនក៏បានលើកឡើងបន្ថែមទៀតថា កម្មវិធី Word Excel និងPowerPoint អាចទាញយកបានលើ Windows Store Beta ៕

# Fire Alarm system






## CM-P1-20L

Fire Alarm Control Panel

20L w/ no-voltage board, Tel Set,
-Zone range is from 5 to 100 zones.
- 2 stages accumulation function to prevent from false alarms.
- With no voltage output contacts and voltage contacts.
-The unit also can combine with our broadcast host and emergency telephone into 3-in-1 system for multipurpose.

## CM-P3-24L

Fire Alarm Control Panel 24L (Grey)

- Zone range is from 1 to 24 zones.
- Key-controlled function switches prevent false alarms caused by accidental touch.
- The fire alarm circuit and indicator circuit are able to detect circuit break and offer protection against short circuit.



---




## CM-FP1

Fire Manual Call Point

- Auto-Return by pushing button, no need to disassemble the main body. Response light available to identify the operation completed.
- Reinforced transparent protective cover is reusable.
* All plastics are fire-proof



## CM-FB6

Fire Alarm Bell 6"

The way of motor-driven is taken at the low consumption of current, to reduce the load for power output from receiver terminal.

## CM-FL1

Fire Indicating Lamp

- Plug-in type of Termination for ease of installation.
- Highly visible. - SMD LED gives high brightness while it has lower power consumption.



---



## CM-RD999

Residential Photoelectric Smoke Detector

- Quickly detect the slow combustion and the fire source of the smolder.
- Attach hook, easy to install, remove and maintenance without any wiring.
- When battery is low, alarm signal will be sent(buzz once peer 40 sec.). Meanwhile, it can normally operate about 30 days. Built-in warning audio over 85 dB and red LED indicator can indicate the fire source.



## CM-WK24L

Fixed Temperature Heat Detector

- Dual LEDs for 360-degree visibility.
- Stabilized performance, long-term durability and least-malfunction are ensured by employing a UL approved sensor.
- The sensitive part is enclosed to prevent from being moistened and contaminated.
- Self-restoring function ensures the elements repeatedly use.

## CM-WS25L

Rate of Rise Heat Detector

- Mechanical operating principles ensure the long-term durability and the least malfunction.
- Self-restoring function ensures the elements repeatedly use.
- Detector has passed EMC test, which greatly eliminates false alarms caused by interference from nearby sources.
- Red indication lamp lights when detector is activated.
ISO 9001, CE Approval, UL (Pending).



## CM-WTK55

Combination Smoke and Heat Detector

Multi-purpose Design: when there is smoke or heat during pre-fire perriod situation will vary due to different environments.this combination Design is to ensure that the pre-fire confirmation will not beaffected by varying environments.this detector has passed strict quality control and repetitive testing ,hence its quality is stable and highly.



PowerColor




## TurboDuo R9 290 4GB GDDR5 OC



- Part NumberAXR9 290 4GBD5-TDHE/OC
- Graphics Engine RADEON R9 290
- Video Memory4GB GDDR5
- Engine Clock975MHz
- Memory Interface512bit
- DirectX® Support11.2
- Bus Standard PCIE 3.0
- Display Connectors DL DVI-D/DL DVI-D/HDMI/DP

## TurboDuo R9 280X 3GB GDDR5 OC



- Part NumberAXR9 280X 3GBD5-T2DHE/OC
- Graphics Engine RADEON R9 280X
- Video Memory3GB GDDR5
- Memory Clock1500MHz x4 (6.0 Gbps)
- Memory Interface384bit
- DirectX® Support11.2
- Bus Standard PCIE 3.0
- Display Connectors DL-DVI/HDMI/Mini Display Port x2

## PCS+ R9 270X 2GB GDDR5



- Part NumberAXR9 270X 2GBD5-PPDHE
- Graphics Engine RADEON R9 270X
- Video Memory2GB GDDR5
- Memory Clock1425MHz (5.7Gbps)
- Memory Interface256bit
- DirectX® Support11.2
- Bus Standard PCIE 3.0
- Display Connectors DL-DVI-I/DL-DVI-D/HDMI/Display

## TurboDuo R9 270 2GB GDDR5 OC



- Part NumberAXR9 270 2GBD5-TDHE/OC
- Graphics EngineRADEON R9 270
- Video Memory2GB GDDR5
- Memory Clock1400MHz (5.6Gbps)
- Memory Interface256bit
- DirectX® Support11.2
- Bus StandardPCIE 3.0
- Display ConnectorsDL DVI-I/ HDMI/ DisplayPort

## TurboDuo R7 265 2GB GDDR5 OC



- Part NumberAXR7 265 2GBD5-TDHE/OC
- Graphics Engine RADEON R7 265
- Video Memory2GB GDDR5
- Memory Clock1400MHz (5.6Gbps)
- Memory Interface256bit
- DirectX® Support11.2
- Bus Standard PCIE 3.0
- Display Connectors DL-DVI-I/ HDMI/ Display Port

## R7 250 2GB GDDR5



- Part NumberAXR7 250 2GBD5-4DL
- Graphics Engine RADEON R7 250
- Video Memory2GB GDDR5
- Memory Clock1125MHz x 4 (4.5 Gbps)
- Memory Interface128bit
- DirectX® Support11.1
- Bus Standard PCIE 3.0
- Display Connectors Mini Display Port x4

## R7 250 1GB GDDR5 OC



- Part NumberAXR7 250 1GBD5-HV2E/OC
- Graphics Engine RADEON R7 250
- Video Memory1GB GDDR5
- Memory Clock1150MHz (4.6Gbps)
- Memory Interface128bit
- DirectX® Support11.2
- Bus Standard PCIE 3.0
- Display Connectors DL-DVI-D/HDMI/VGA

## R7 250 2GB DDR3



- Part NumberAXR7 250 2GBK3-HE
- Graphics Engine RADEON R7 250
- Video Memory2GB DDR3
- Memory Clock800MHz x 2
- Memory Interface128bit
- DirectX® Support11.2
- Bus Standard PCIE 3.0
- Display Connectors DL-DVI-D/HDMI/VGA

ទស្សនាវដ្ដី
# ទីក្រុងទូរស័ព្ទ
PHONE CITY MAGAZINE

MAGAZINE




## ចេញផ្សាយរៀងរាល់ថ្ងៃទី ០១ នៃខែនីមួយៗ

### ផ្តល់ជូននូវ:

| | | | |
|---|---|---|---|
| ម៉ូដែលទូរស័ព្ទថ្មីៗ និងរបៀបប្រើប្រាស់ទូរស័ព្ទ | តារាងតម្លៃទូរស័ព្ទ | អត្ថបទកម្សាន្ត យ៉ាងសម្បូរបែប | ងាយស្រួលទាញយក តាមរយៈ Smart Phone ឬ Website |

អតិថិជនមិត្តអ្នកអានទាំងអស់អាចទាញយកទស្សនាទីក្រុងទូរស័ព្ទបានដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.phonecity.com.kh ឬសម្រាប់អ្នកប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការ Android អាចទាញយកកម្មវិធី Phonecity បានតាមរយៈ Playstore ។

MAGAZINE

# មាតិកា

លេខទី១៨៤ ខែមីនា ឆ្នាំ២០១៥
184 March 2015




## ព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ

12- អ្នកសម្ភារៈនិយមនាំគ្នាផ្អើល ....................
15- Hacker សញ្ជាតិឥណ្ឌាម្នាក់ត្រូវបានចាប់ខ្លួន ...
18- អត្ថប្រយោជន៍បច្ចេកវិទ្យាសុវត្ថិភាពទាំង៥ ប្រភេទដែលមិនគួរមើលរំលង .....................
19- តើអ្វីជា Samsung Galaxy បន្ទាប់.............
20- វេទិការ Mobile World Congress ..........
22- Privacy policy របស់ google .............

## Accessories Computer

23- Logitect M510 Wireless Mouse ...
24- SwissGear Laptop Bag ...............
25- Multi-Touchpad K400 ....................
26- USB Drive Voice Recorder ..........

## Computer Review

28- Asus G751................................
30- Lenovo Yoga 3 Pro .........................
32- Dell Inspiron Small .........................
34- Thinkcentre E63z ...........................

## HardWare Review

36- GEFORCE GTX 980 សមត្ថភាពខ្លាំងពិសេសបំផុត ..........................
38- SAPPHIRE R9 290 រូបរាងថ្មីទាន់សម័យ សមត្ថភាពកាន់តែខ្ពស់.................................

## New Software

40- កម្មវិធីថ្មីៗ ............................................

## Software Review

44- គ្រប់គ្រង Project បានយ៉ាងងាយស្រួល ជាមួយ Project KickStart Pro 5.................

## Top Ten Computer

48 - ជម្រើសទាំង១០សម្រាប់កុំព្យូទ័រយួរដៃ



AFFORDABLE RELIABLE INTERNET

CITY Link

YOUR OBVIOUS CHOICE

LEADING INTERNET SERVICE PROVIDER

# 1Mbps get 2Mbps
# 2Mbps get 4Mbps




023 220 112

www.citylink.com.kh

# មាតិកា

លេខទី១៨៤ ខែមីនា ឆ្នាំ២០១៥
184 March 2015





**Security**

52- វិធីសាស្រ្តធំៗ១០យ៉ាងដើម្បីការពារព័ត៌មានអ្នកនៅលើអ៊ីនធើណេត.............................

**Quick Study**

55- កំណត់ពេលវេលាបិទកុំព្យូទ័ររបស់អ្នក........

57- របៀបប្រើប្រាស់ Desktop បានច្រើន .....

60- របៀបចាក់តន្ត្រី Youtube នៅក្នុង ...........

**Top Game**

62 - ហ្គេមកុំព្យូទ័រពេញនិយម

**សំណួរមិត្តអ្នកអាន**

75 - សំណួរ និងចម្លើយ

**តារាងតម្លៃ**

79- តារាងតម្លៃកុំព្យូទ័រ និងគ្រឿងបន្លាស់

**ហ្គេមថ្មីៗ**

88- កែវភ្នែកអាទិទេព PNEUMA

**ផលិតផលថ្មីៗ**

86- QNAP TS-651 .............................

87- តេស្តឈាមដ៏ងាយបំផុតជាមួយ accessory .............................................

90- RX 290X.........................................

93- Lockitron បើកទ្វារផ្ទះដោយមិនប្រើសោរ.....

94- កាបូបសំលៀកបំពាក់អេឡិចត្រូនិច .........

96- Pioneer BDR-XS06JM................

97- Robot សរសេរម៉ោងលើបន្ទះក្តារ ........


**ចាងហ្វាងការផ្សាយ**
អនុបណ្ឌិត : ប៊ុល ច័ន្ទវីរៈ

**នាយកគ្រប់គ្រង**
Mr. : JACKY SAM

**ប្រធានផ្នែកព័ត៌មាន និងនិពន្ធ**
លោក : ឆាន សុផា

**ផ្នែកព័ត៌មាន និងនិពន្ធ**
កញ្ញា : ប៉ោក លក្ខិណា
លោក : ម៉ម សុវណ្ណថា
កញ្ញា : សៀង ចាន់ថូ

**ផ្នែករចនាទំព័រ**
ប្រធានលោក : ស្វាយ សេរីវុត្ថា
លោក : រស់ ចំរើន

**ផ្នែកទីផ្សារ**
កញ្ញា : យ៉ែម រដ្ឋា

**ផ្នែកលក់**
លោក : វង់ តុលា

**ផ្នែកគេហទំព័រ**
លោក : ឆាន សុផា
កញ្ញា : ប៉ោក លក្ខិណា

អាសយដ្ឋាន : ផ្ទះលេខ ៨ AEo
ផ្លូវលេខ ១៥៦ សង្កាត់វាលវង់
ខណ្ឌ ៧មករា រាជធានីភ្នំពេញ

**ទំនាក់ទំនងផ្សាយពាណិជ្ជកម្ម**
**010 67 67 67**
**018 333337**









# បច្ចេកវិទ្យាចុងក្រោយក្នុងការព្រីន
# CONFIDENTIAL CODE



ផ្ញើលេខកូដទៅកាន់អតិថិជនរបស់អ្នកនៅក្នុងវិធីដ៏មានសុវត្ថិភាព
**100%** ជាមួយនឹងការច្នៃប្រឌិតថ្មីបំផុតរបស់យើង។




### ប្រសិទ្ធភាព
សាមញ្ញ ងាយស្រួលអនុវត្តន៍
និងងាយស្រួលប្រើប្រាស់

### ភាពអាចកំបាំង
ព័ត៌មានសម្ងាត់អានបានតែម្តងប៉ុណ្ណោះ
មិនអាចត្រឡប់ម្តងទៀតបានទេ

### សុវត្ថិភាព
ព័ត៌មានធានាសុវត្ថិភាពទាំងស្រុង
ក្នុងអំឡុងពេល និងបន្ទាប់ពីការបោះពុម្ព



ធនាគារអឺរ៉ុប និងក្រុមហ៊ុនធានារ៉ាប់រងជាច្រើនកំពុងប្រើបច្ចេកវិទ្យារបស់យើង:

AIR FRANCE · Banque Accord · Caisse d'Epargne · castorama · cetelem · FINAREF · LA POSTE · GE · MACSF groupe · oney · PEUGEOT · Société Générale ...

#8AE0, Sangkat Veal Vong, Khan 7 Makara,
Phnom Penh City, Cambodia
Tel: (855) 16 555 889 / 018 333337

# អ្នកសម្ភារៈនិយមនាំគ្នា ផ្អើលប្រើ HUAWEI G7 យ៉ាងភ្លូកទឹកភ្លូកដី




ជាមួយនឹងបទពិសោធន៍អាជីវកម្មដ៏លើសលប់ផ្នែកបច្ចេកវិជ្ជាព័ត៌មាន និងទូរគមនាគមន៍(ICT) អស់រយៈពេលជាង២០ឆ្នាំ ជាបណ្តាញសកលដ៏ទូលំទូលាយប្រតិបត្តិការអាជីវកម្មលំដាប់ពិភពលោក ព្រមទាំងជាដៃគូដ៏មានបទពិសោធន៍ គ្រុបអាជីវកម្មសម្រាប់អតិថិជន Huawei (BG) បានប្តេជ្ញាពាំនាំយកបច្ចេកវិជ្ជាចុងក្រោយបំផុតជូនដល់អតិថិជនផ្តល់ជូនពិភពលោកនូវលទ្ធភាពនានា និងការបង្កើតបទពិសោធន៍ដ៏អស្ចារ្យសម្រាប់អ្នកប្រើប្រាស់គ្រប់ទីកន្លែង ។

គួរកត់សម្គាល់ថា យុវវ័យសម័យស្មាតហ្វូននេះនាំគ្នាផ្អើលមកប្រើគ្រប់ ៗ គ្នានូវផលិតផល HUAWEI ក្នុងទីផ្សារកម្ពុជាចុងឆ្នាំ ២០១៤ នេះ ដោយចាប់ផ្តើមពី HUAWEI Mate 7, Honor 6 និងចេញស៊េរីកាចៗបន្ថែមទៀតក្នុងឆ្នាំ ២០១៥ នេះដែរដូចជា៖ G7, Honor 6 plus, X2, P8, Mate 8, G8 ដើម្បីផ្តួលម៉ាកផ្សេងៗទៀត ដែលមានអត្ថប្រយោជន៍ប្រហាក់ប្រហែលឬអន់ជាងតែតម្លៃថ្លៃជាង។ អត្ថប្រយោជន៍ និងសមត្ថភាពមិនធម្មតារបស់ HUAWEI G7 មានដូចជា៖ អេក្រង់ធំពេញភ្នែក ទំហំ ៥,៥ អ៊ីញ HD IPS LTPS Display (1280X720 pixels) អង្គប្រតិបត្តិការ Quad-core Qualcomm MSM8916 12.GHz ល្បឿនអង្គចងចាំ RAM: 2GB និងទំហំផ្ទុកទិន្នន័យ ROM 16GB និងអាចបន្ថែមអង្គចងចាំរហូតដល់ 32GB ជាពិសេសបច្ចេកវិទ្យាទំនើបៗនៃកាមេរ៉ាដែលមានទំហំ 13PM និង 5MP ដោយបំពាក់បច្ចេកវិទ្យាថតរូបលឿនដោយមិនចាំបាច់បើកទូរស័ព្ទ (Ultra snapshot) ត្រឹមតែ ១,៤ វិនាទី កាមេរ៉ាមុខថតសែលហ្វីផ្តេកទ្រវែង បានទូលាយច្បាស់ និងកាមេរ៉ាក្រោយថត Panorama ផ្តេកទ្រវែង និងបញ្ឈរ។ ជាងនេះទៅទៀត កាមេរ៉ាបានបន្ថែមនូវមុខងារថ្មីៗ ដូចជាមុខងារ ថតរូបស្អាត បញ្ជាដោយសំឡេង ថតរូបជាប់ជាមួយសំឡេង ១០វិនាទី រួមទាំងវីដេអូមានមុខងារថត All focus។ ដោយសារតែយុវវ័យសម័យស្មាតហ្វូននាំគ្នាផ្អើលប្រើ HUAWEI G7 យ៉ាងភ្លូកទឹកភ្លូកដី ជាពិសេសក្រុមអ្នក high class ចង់ទិញ និងប្រើបែបនេះហើយ ទើបធ្វើឲ្យ HUAWEI G7 លក់អស់២០០០គ្រឿង ត្រឹមតែ៧ថ្ងៃបន្ទាប់ពីនាំចូលមកលក់ក្នុងសប្តាហ៍ដំបូង។ HUAWEI G7 មានពីរពណ៌ ទឹកប្រាក់ ពណ៌ខ្មៅ ស៊ីម ១ ដែលមានលក់សព្វថ្ងៃនេះ និងស៊េរីខ្ពស់ពណ៌ទឹកប្រាក់ស៊ីម២ ក្នុងពេលឆាប់ៗនេះ។

> អ្វីដែលជាចំណុចទាក់ទាញដ៏ខ្លាំងក្លារបស់ HUAWEI G7 នោះគឺរូបរាង ថ្មកាមេរ៉ា និងល្បឿនអ៊ីនធើណេតលឿនអស់ស្ទះ។ បើនិយាយពីរូបរាងគឺទាក់ទាញ ស្តើង ស្រាល មាំ ជាមួយនឹងតួទាំងមូលស្រោបលោហធាតុដែលមាំ ធន់ មិនរបកថ្នាំ ឬទន់ដោយប្រើជ័រទន់ ឬជ័រស្រួយ ឬសម្ភារៈដែលងាយបែក ឬខូចដែលគ្រាន់តែបាញ់ថ្នាំពណ៌ អ៊ីណុកដូច ម៉ាក ផ្សេងៗ ឡើយ។ ជាពិសេសកាមេរ៉ាកាន់តែអ៊ែមជាមួយនឹងកាមេរ៉ាសែលហ្វី អស់ទាស់ និងមុខងារទំនើបៗថ្មី ។ បើនិយាយពីថ្មវិញគឺវាជាច់ម៉ាកផ្សេងៗដែលប្រើបានតែកន្លះថ្ងៃ ឬពីព្រឹកដល់រសៀល មិនអាចផ្ទៀប HUAWEI G7 ដែលអាចប្រើពីព្រឹកដល់ល្ងាច ឬយប់។

គួរបញ្ជាក់ផងដែរថា ក្រុមហ៊ុន Huawei Consumer BG មានមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍចំនួន១៦ នៅក្នុងប្រទេសជាច្រើន រួមមានប្រទេសអាល្លឺម៉ង់ ស៊ុយអែត អាមេរិក បារាំង អ៊ីតាលី រុស្ស៊ី ឥណ្ឌា និងចិន ផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុន Huawei ពង្រីកដល់ជាង១៧០ ប្រទេស កំពុងបម្រើមួយភាគបីនៃចំនួនប្រជាជនសរុបក្នុងពិភពលោក។ នៅឆ្នាំ ២០១៤ ការនាំចេញស្មាតហ្វូនរបស់ក្រុមហ៊ុន Huawei បានជាប់លំដាប់ថ្នាក់លេខបីនៅលើពិភពលោក។ គ្រុបអាជីវកម្មមួយ ក្នុងចំណោមគ្រុបអាជីវកម្មបីរបស់ក្រុមហ៊ុន Huawei មានដូចជាគ្រុបអាជីវកម្មសម្រាប់អតិថិជន Huawei (BG) ដែលចែកចាយនូវផលិតផលរួមមានទូរស័ព្ទដៃ ឧបករណ៍អ៊ីនធើណេតតាមទូរស័ព្ទ (MBB) និងឧបករណ៍អ៊ីនធើណេតតាមផ្ទះ ៕

*សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ៖*
*consumer.huawei.com*


EMAXX™ 4G
Internet - WIMAX - Fiber Optics - Telecom Services
4G SPEED
AT YOUR
FINGERTIPS
No. 99, Preah Norodom,
Level 1, Phnom Penh
info@emaxxtelecom.com
www.emaxxtelecom.com
023 999 818
YOUR INTERNET
SERVICE PROVIDER

MEKONGNET
CONNECTING YOU ALL

# Beyond ISP-Your Preferred ICT Solutions Provider

" Beyond 10Gbps network "




**Internet | IPLC/DPLC/VPN | Cloud Services | Data Center**
**Media Services | Managed Services | Wholesale | ICT Solutions**

4th floor, AnAnA Building #95, Preah Norodom Blvd., Sangkat Boeung Raing, Khan Daun Penh, Phnom Penh.

023 22 66 22 sales@corp.mekongnet.com.kh www.mekongnet.com.kh Mekongnet ISP




# Hacker សញ្ជាតិឥណ្ឌាម្នាក់រហ័សនាម "The Messiah" ត្រូវបានគេចាប់ដាក់ពន្ធនាគា

មួយរយៈកាលចុងក្រោយនេះមានបញ្ហា Hack ជាច្រើនកើតឡើងស្ទើរតែទូទាំងសាកលលោក។ ក្រុមហ៊ុន Sony និងបណ្ដាវិបសាយធំៗជាច្រើនត្រូវបានគេ Hack។ ថ្មីៗនេះនៅប្រទេសឥណ្ឌាក៏មានរឿង Hack ជាច្រើន ហើយពេលនេះគេចាប់បានអ្នក Hack ម្នាក់។

បុរសសញ្ជាតិឥណ្ឌាម្នាក់ត្រូវបានគេចាប់ដាក់ពន្ធនាគាចំនួន 04 ឆ្នាំ និង 08 ខែពីបទ hack លើបណ្ដាញកុំព្យូទ័រអង្គការចំនួនប្រាំពីរ ។ James Raj Arokiasamy ដែលត្រូវបានគេដាក់រហ័សនាមថា "The Messiah" ត្រូវបានគេចោទប្រកាន់តពីបទ Hack កាលពីសប្ដាហ៍មុន។

ក្នុងការ Hack លោក Raj បានប្រើប្រាស់ software ដើម្បីស្កែនលើ server ជាច្រើនរបស់រដ្ឋាភិបាល ក្នុងនោះរួមមានserver របស់ Office របស់នាយករដ្ឋមន្ត្រី និងផ្នែក Elections Department។ Community Foundation អ្នកត្រួតពិនិត្យ និងប្រឹក្សាក្នុងក្រុងជាអ្នកទទួលភារកិច្ចគ្រប់គ្រងរឿងនេះ។



លោកបានឱ្យដឹងថា គេហទំព័រជាច្រើនត្រូវមានបញ្ហា និងត្រូវបានបំផ្លាញ ហើយលោក Raj ក៏បាន Hack វិបសាយ Straits Times blog និងចូលដំណើរការដោយសំងាត់លើ server ដែលផ្ទុកឯកសាររបស់ធនាគារ Standard Chartered Bank ៕

ANANA
TRUSTED SERVICE & QUALITY

## AUTHORIZED DISTRIBUTOR OF:

HIP® Highest Ideas Products

DELL

VIVOTEK

EMERSON™ Network Power

AVIRA

Schneider Electric

TEAM NISCA

Logitech

Power Tree

Targus

Verbatim®

**Address** : Building #95, Preah Norodom Blvd, Beoung Raing, Khan Daun Penh, Phnom Penh, Cambodia. (Opposite to Chaktomuk Secondary School)
**mPhone** : 023 211 543 H/P: 087 277 709 | 010 831 516 | 070 27 77 09
**eMail** : sales@ananacomputer.com | www.ananacomputer.com

# 1.5 MB SPEED

## UPLOAD 3MB

# 25$

**GET ONE MONTH FREE**

Wicam
The best connection

#113, St. 271, Sangkat Boeung Salang, Khan Toul Kok, Phnom Penh.
Telephone: (855) 23 22 40 40 / (855) 23 22 25 35
Fax: (855) 023 22 25 26
E-mail:info@wicam.com.kh / sales@wicam.com.kh
facebook.com/wicamcorporate twitter.com/wicamisp

# អត្ថប្រយោជន៍ បច្ចេកវិទ្យាសុវត្ថិភាព ទាំង ៥ប្រភេទ ដែលមិនគួរមើលរំលង



សេដ្ឋកិច្ចប្រទេសកម្ពុជាកើនឡើងយ៉ាងស្រួចស្រាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ ការវិនិយោគទៅលើវិស័យអចលនទ្រព្យ ផ្សារទំនើប និងអាជីវកម្មទាំងខ្នាតតូច និងមធ្យមជាច្រើន បាន នឹងកំពុងរីកដុះដាលយ៉ាងឆាប់រហ័សផងដែរ ប៉ុន្តែអាជីវកម្មដែលទទួលបានភាពជោគជ័យ ព្រមជាមួយនឹងប្រាក់ចំណូលជាវិជ្ជមានប្រចាំឆ្នាំគួរគប្បីត្រូវតែយល់ដឹង និងយកចិត្តទុកដាក់យ៉ាងខ្លាំងបំផុតចំពោះសន្តិសុខ សុវត្ថិភាព អតិថិជន ធនធាន ទ្រព្យសម្បត្តិ និងបុគ្គលិកឲ្យបានល្អបំផុត។

ពេលនេះយើងសូមលើកយក ប្រព័ន្ធបច្ចេកវិទ្យា សន្តិសុខ សុវត្ថិភាព ៥ប្រភេទ ដ៏រឹងមាំ និងសុវត្ថិភាពបំផុតសម្រាប់អាជីវកម្ម របស់លោកអ្នក។ ប្រព័ន្ធសុវត្ថិភាពទាំងអស់នេះនឹងជួយឲ្យការវិនិយោគឬអាជីវកម្មរបស់លោកអ្នក ទទួលបាននូវការការពារ នឹងទប់ទល់ទៅនិងការបាត់បង់សម្ភារៈរបស់បុគ្គលិក និងអតិថិជនៈ

## ១. កាមេរ៉ាវីដេអូ សុវត្ថិភាព ( Video Surveillance)

ប្រព័ន្ធកាមេរ៉ាវីដេអូសុវត្ថិភាពដែលរួមមានប្រភេទជា Analog, Thermal និងប្រើដោយ IP គឺជាប្រភេទកាមេរ៉ាផ្តល់សុវត្ថិភាព និងសន្តិសុខដ៏មានប្រសិទ្ធិភាពបំផុតចំពោះក្រុមហ៊ុនសហគ្រាស ឬក៏អាជីវកម្មរបស់លោកអ្នក។ វាធានាបានជាអតិបរិមាពីសុវត្ថិភាពទាំងអតិថិជន និងទ្រព្យសម្បត្តិរបស់លោកអ្នក។ CCTV សន្សំសំចៃខ្ពស់ ទៅលើការចំណាយផ្សេងៗ ពីព្រោះវាមានបច្ចេកវិទ្យាខ្ពស់បំផុតសម្រាប់រក្សាសុវត្ថិភាពបុគ្គលិកនិងអតិថិជន។ ប្រភេទកាមេរ៉ាទាំងអស់នេះផ្តល់ព័ត៌មាន និងទីតាំងដ៏ជាក់លាក់បំផុតនឹងអាចផ្លាស់ប្តូរពីតាំងមួយទៅទីតាំងផ្សេងៗទៀត។ វាថតរាល់សកម្មភាពទាក់ទងនឹងចោរកម្ម ការបន្លំ ពីបុគ្គលិក ឬក៏ពីអតិថិជនខិលខូច។ មិនតែប៉ុណ្ណោះ វាក៏អាចគ្រប់គ្រងច្រកចេញចូលរបស់ក្រុមហ៊ុនអាជីវកម្មលោកអ្នកដ៏មានប្រសិទ្ធិភាពផងដែរ។

## ២. ប្រព័ន្ធគ្រប់គ្រងច្រកចេញចូល (Access Control)

ប្រព័ន្ធគ្រប់គ្រងច្រកចេញចូល (Access Control )គឺជាជម្រើសដ៏ល្អបំផុតដើម្បីការពារសុវត្ថិភាព ច្រកចេញចូលទៅកាន់ទីតាំង និងទីកន្លែងសំខាន់ៗផ្សេងៗនៃទីតាំងអាជីវកម្ម ក្រុមហ៊ុន សហគ្រាស ផ្សារទំនើប នានា ។ ប្រព័ន្ធគ្រប់គ្រងច្រកចេញចូល មិនត្រឹមតែជួយការពារឯកសារ សម្ភារៈ និងសន្តិសុខ សុវត្ថិភាពផ្សេងៗក្នុងទីតាំងអាជីវកម្មរបស់លោកអ្នកប៉ុណ្ណោះទេ វាថែមទាំងជួយកាត់បន្ថយនូវហានិភ័យខ្ពស់ពីការរំខាននៅក្នុងកន្លែងការងារនិងទីតាំងអាជីវកម្មរបស់លោកអ្នក ព្រមទាំងជួយការពារបុគ្គលិក និងអតិថិជន ចំពោះការចេញចូលកន្លែងការងារឬទីតាំងអាជីវកម្មរបស់លោកអ្នកដោយមិនមានការអនុញ្ញាតផងដែរ។

## ៣. ប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងប្រាក់បៀវត្សរ៍ ( Payroll System)

យើងដឹងថាក្រុមហ៊ុនអាជីវកម្មរបស់លោកអ្នកពិតជាជួបនូវផលលំបាកជាច្រើនចំពោះការគ្រប់គ្រងបុគ្គលិក ប្រាក់បៀវត្សរ៍ និងបញ្ហាពីសុវត្ថិភាពផ្សេងៗទាក់ទងនិងប្រាក់ខែរបស់បុគ្គលិក។ ជម្រើសដ៏វៃឆ្លាតបំផុត ដើម្បីជួយសម្រាលផលលំបាកទាំងអស់នោះ យើងសូមណែនាំលោកអ្នកនូវប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងប្រាក់បៀវត្សរ៍បុគ្គលិក(Payroll System)។ ប្រព័ន្ធមួយនេះមានមុខងារច្រើនជាងការគណនាប្រាក់បៀវត្សរ៍ និងព្រីនបញ្ជីប្រាក់ខែនោះទៅទៀត។ វាផ្តល់អ្នកប្រើប្រាស់នូវការគ្រប់គ្រងការចំណាយរបស់ក្រុមហ៊ុនទៅលើការងាររបស់បុគ្គលិក។ ជាងនេះទៅទៀត វាក៏ជួយដល់ផ្នែកធនធានមនុស្សឲ្យដំណើរការបានយ៉ាងរលូនផងដែរ។ ប្រព័ន្ធដ៏ទំនើបមួយនេះនឹងគណនា ប្រាក់បៀវត្សរ៍ អត្រាកាត់ពន្ធជូនរដ្ឋ សេវាធានារ៉ាប់រងសុខភាព និងសេវាផ្សេងៗទៀតរបស់បុគ្គលិកម្នាក់ៗប្រចាំខែនីមួយៗ បានយ៉ាងជាក់លាក់ មិនតែប៉ុណ្ណោះវាផ្តល់អ្នកប្រើប្រាស់នូវការគ្រប់គ្រងដ៏ល្អទៅនិងទិន្នន័យផ្សេងៗ ព្រមទាំងកាត់បន្ថយពេលវេលាលើការគណនាបានយ៉ាងរហ័ស។

## ៤. ប្រព័ន្ធគ្រប់គ្រងចំណតយានយន្ត( Car Parking System )

បញ្ហាបាត់បង់សម្ភារៈផ្សេងៗដូចជា ការបាត់បង់រថយន្ត ម៉ូតូ របស់បុគ្គលិក និងអតិថិជនតែងតែកើតមានជារឿយៗនៅតាមបណ្តាចំណតយានយន្តមួយចំនួននៅក្នុងរាជធានីភ្នំពេញ ក៏ប៉ុន្តែបញ្ហាទាំងអស់នោះមិនពិបាកក្នុងការគ្រប់គ្រងនោះទេ បើសិនជាចំណត់យានយន្តលោកអ្នកបំពាក់ប្រព័ន្ធគ្រប់គ្រងចំណតយានយន្ត។ ប្រព័ន្ធគ្រប់គ្រងចំណតយានយន្តមួយនេះ និងជួយឲ្យទ្រព្យសម្បត្តិរបស់បុគ្គលិក អតិថិជនរបស់លោកអ្នកមានសុវត្ថិភាព នឹងផ្តល់អ្នកប្រើប្រាស់យានយន្តនូវភាពងាយស្រួលក្នុងការប្រើប្រាស់ចំណត ជាពិសេសចំណតក្នុងផ្សារទំនើប និងក្រុមហ៊ុនអាជីវកម្មផ្សេងៗដែលស្ថិតនៅទីប្រជុំជន។ ប្រព័ន្ធគ្រប់គ្រងចំណតយានយន្ត ជួយសន្សំសំចៃពេលវេលាប្រាក់កាក់ ហើយនឹងបង្កភាពងាយស្រួល និងកាត់បន្ថយភាពនឿយហត់ក្នុងការរកចំណត។ វានឹងផ្តល់ដំណឹងពីភាពមិនប្រក្រតីក្នុងចំណតចំពោះបញ្ហាផ្សេងៗ ។

## ៥. ប្រព័ន្ធគ្រប់គ្រងការចេញចូលរបស់អតិថិជន ( Visitor Management System)

គ្រប់ក្រុមហ៊ុនផ្សារទំនើប ឬក៏អាជីវកម្មទាំងអស់តែងតែផ្តល់តម្លៃដល់អតិថិជនថាជាស្តេច ដូច្នេះរាល់តម្លៃ ទីតាំង សម្ភារៈ នានា ត្រូវបានរៀបចំប្រកដដោយភាពទាក់ទាញដើម្បីបម្រើដល់អតិថិជនក្នុងន័យមួយគឺចង់ឲ្យមានអតិថិជនចេញចូលឲ្យបានច្រើនក្នុងហាង ក្រុមហ៊ុនអាជីវកម្មរបស់ពួកគេ។ យ៉ាងណាមិញ សុវត្ថិភាពអតិថិជន សម្ភារៈ របស់អ្នកក៏ដូចជាសម្ភារៈរបស់អតិថិជនក៏ត្រូវបានការពារដោយយកចិត្តទុកដាក់ផងដែរ។ ក្រុមហ៊ុន សហគ្រាស ផ្សារទំនើប និងអាជីវកម្មដែលគិតគូពីសុវត្ថិភាពទាំងអស់នោះគួរតែមានប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងអតិថិជន។ ប្រព័ន្ធបច្ចេកវិទ្យាប្រភេទនេះគឺតាមដានរាល់ការចេញចូលរបស់អតិថិជន ឬភ្ញៀវដែលចូលមកកាន់ក្រុមហ៊ុន និងទីតាំងអាជីវកម្មរបស់លោកអ្នក។ ជាមួយនិងប្រព័ន្ធទំនើបនេះ លោកអ្នកមានសមត្ថភាពក្នុងការពន្លឿននូវដំណើរការចុះឈ្មោះ កំណត់គោលដៅអតិថិជនណាមួយដែលស្ថិតនៅក្នុងក្រុមហ៊ុននឹងផ្តល់ដំណឹងចំពោះភ្ញៀវដែលមានចេតនាក្នុងកន្លែងហាមឃាត់។ ប្រព័ន្ធដែលបំពាក់ឡើងជាមួយបច្ចេកវិទ្យាចុងក្រោយបង្អស់មួយនេះនឹងពង្រឹងសន្តិសុខ សុវត្ថិភាពនៅក្នុងក្រុមហ៊ុន នឹងនាំមកនូវអារម្មណ៍សុខសុវត្ថិភាពចំពោះបុគ្គលិក និងភ្ញៀវរបស់លោកអ្នក នឹងបង្ហាញពីការយកចិត្តដាក់ដ៏អស្ចារ្យដល់អតិថិជន និងធ្វើឲ្យប្រសើរឡើងនូវមុខមាត់ក្រុមហ៊ុនផងដែរ ៕

**ដោយ សុខ ចាន់, ក្រុមហ៊ុន មេគង្គណិត**









# តើអ្វីជា Samsung Galaxy បន្ទាប់ ?




បន្ទាប់ពីធ្វើឲ្យពិភពលោកភ្ញាក់ផ្អើលដោយការឈ្នះបានពានរង្វាន់រហូតដល់ទៅ ៨០ រង្វាន់ មិនបានប៉ុន្មានផង ក្រុមហ៊ុន Samsung ក៏ធ្វើឲ្យបណ្តាញសារព័ត៌មានអន្តរជាតិ និងក្នុងស្រុកកក្រើកជាថ្មីម្តងទៀត តាមរយៈខ្សែវីដេអូផ្សាយពាណិជ្ជកម្មដ៏អាថ៌កំបាំងបន្តបន្ទាប់ដែលបង្ហើបជាមួយសារមួយឃ្លាថា “I am the Next Galaxy” មានន័យជាភាសាខ្មែរថា «ខ្ញុំគឺជា Galaxy បន្ទាប់»។

ខ្សែវីដេអូទាំងនេះពិតជាធ្វើឲ្យសាធារណៈជនទូទាំងពិភពលោក រួមទាំងអ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមនៅកម្ពុជាយើងនេះ មានភាពងឿងឆ្ងល់ និងរង់ចាំយ៉ាងអន្ទះសា ចង់ដឹង ចង់ឃើញ Samsung Galaxy បន្ទាប់នេះថាជាប្រភេទទូរស័ព្ទអ្វី។

វីដេអូដែលពោរពេញទៅដោយចម្ងល់នេះក៏ត្រូវបាន Post និង Share តៗគ្នានៅលើបណ្តាញសង្គមស្ទើរតែគ្រប់គ្នា។ មិនត្រឹមតែប៉ុណ្ណោះ គេក៏ឃើញមានវីដេអូនេះនៅលើទំព័រ Facebook របស់កំពូលតារាចម្រៀងដ៏ល្បី កញ្ញា **ឱក សុគន្ធកញ្ញា** និងតារាសម្តែងដ៏លេចធ្លោ កញ្ញា **មាន សុនីតា** ផងដែរ។

យើងបានដឹង និងឃើញស្រាប់ហើយថារាល់កំពូលឧបករណ៍អេឡិចត្រូនិករបស់ Samsung ចេញមកមួយៗ ពិតជាធ្វើឲ្យពិភពលោកកក្រើក និងទទួលបានការគាំទ្រយ៉ាងខ្លាំងលើរូបរាងរចនាយ៉ាងប្រណិតស្រស់ស្អាត ព្រមទាំងមុខងារប្រើប្រាស់ប្រកបដោយគុណសម្បត្តិគ្មានពីរសម្រាប់ជាប្រយោជន៍ និងភាពងាយស្រួលដល់អ្នកប្រើប្រាស់ ដូចជាកំពូលស្មាតហ្វូន Galaxy Note 4, ថេប្លេត Samsung Galaxy Tab S និងថ្មីៗនេះគឺទូរស័ព្ទកាលីប Samsung Galaxy A ដែលកំពុងទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីយុវវ័យទាន់សម័យ។

Samsung Galaxy បន្ទាប់នេះ ប្រាកដជាអស្ចារ្យ ប៉ុន្តែយើងក៏មិនដឹងថាអស្ចារ្យកម្រិតណានោះដែរ។ មកដល់ពេលនេះមិនទាន់មានប្រភពព័ត៌មានណាចេញមកអះអាងអំពីថ្ងៃដាក់សម្ពោធ Samsung Galaxy បន្ទាប់នេះជាផ្លូវការនៅឡើយទេ តែបើតាមប្រភពព័ត៌មានមិនច្បាស់ការ បានឲ្យដឹងថា ក្រុមហ៊ុនត្រៀមនឹងបញ្ចេញទូរស័ព្ទស៊េរី Galaxy E និង Galaxy J ។ បណ្តាអ្នកលេងបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុកមួយចំនួនសង្ស័យថា វាជា Samsung Galaxy S6 ។ ហើយបើតាមព័តមានរបស់គេហទំព័រ www.cnet.com បានឲ្យដឹងដែរថា Samsung Galaxy S6 នឹងបង្ហាញខ្លួនជាផ្លូវការក្នុងសមាជទូរស័ព្ទពិភពលោក World Mobile Congress នៅថ្ងៃទី១ ខែមីនា ។ ដូច្នេះមានតែរង់ចាំមើលទាំងអស់គ្នា ថាតើមានអ្វីភ្ញាក់ផ្អើលពី Samsung នៅថ្ងៃទី១ ខែមីនា ៕







អំណះអំណាង៖

https://www.facebook.com/aok.sokunkanha

https://www.facebook.com/solidusmarketing

https://www.facebook.com/meansonyta

# វេទិកា Mobile World Congress 2015

វេទិកា Mobile World Congress 2015 យ៉ាងធំក្នុងឆ្នាំនេះ មានការចូលរួមបង្ហាញផលិតផលពីសំណាក់ក្រុមហ៊ុនធំៗ។ ក្នុងនោះក្រុមហ៊ុនទាំងអស់បានរៀបចំផលិតផលរបស់ខ្លួនក៏ដូចជាត្រៀមបង្ហាញលក្ខណៈពិសេសរបស់ផលិតទៅដល់ពិភពលោក។

ខាងក្រោមជាឈ្មោះក្រុមហ៊ុន និងចំនួនផលិតផលថ្មីៗដែលក្រុមហ៊ុននាំមកលើវេទិកាអន្តរជាតិនេះ៖

### ក្រុមហ៊ុន Samsung នាំម៉ូដែលឈ្មោះ

ស្មាតហ្វូន Samsung Galaxy S6

ស្មាតហ្វូន Samsung Galaxy S6 Edge




### ក្រុមហ៊ុន HTC

ស្មាតហ្វូន One M9



## ក្រុមហ៊ុន Sony

ស្មាតហ្វូន Xperia M4 Aqua , Sony Xperia Z4 Tablet

Sony SmartWatch 3



## ក្រុមហ៊ុន Huawei

Huawei MediaPad X2, Huawei Watch, Huawei Honor Y635, Huawei Honor Y360 , Huawei Talkband B2 , Huawei Talkband N1



## ក្រុមហ៊ុន Alcatel

OneTouch Idol 3




## ក្រុមហ៊ុន ZTE

ZTE Grand S3




## ក្រុមហ៊ុន Acer

Acer Liquid Jade Z, Acer Liquid Z520, Acer Liquid Z220

Acer Liquid M220, Acer Liquid Leap+ smartband




## ក្រុមហ៊ុន BlackBerry

BBM




## ក្រុមហ៊ុន Lenovo

Tab 2 A10, Tab 2 A8, Ideapad MIIX 300 slates



## ក្រុមហ៊ុន Microsoft

Lumia 640 LTE, Lumia 640 LTE Dual SIM, Lumia 640 Dual SIM, Lumia 640 XL, Lumia 640 XL Dual SIM, Lumia 640 XL LTE, Lumia 640 XL LTE Dual SIM



# Privacy Policy របស់ Google នៅស្រពិចស្រពិល




Search engine Google បានយល់ព្រមជូនដំណឹងទៅកាន់អ្នកប្រើប្រាស់ពីរបៀបរក្សាទិន្នន័យក្រោយពីអ្នកគ្រប់គ្រង និងការពារទិន្នន័យនៅចក្រភពអង់គ្លេសបានធ្វើការស៊ើបអង្កេតលើ privacy policy មានលក្ខណៈស្រពិចស្រពិល។

អ្នកគ្រប់គ្រងបណ្តាញព័ត៌មាន Information Commissioner បានឱ្យដឹងថាក្រុមហ៊ុន Google ត្រូវបានគេទាមទារឱ្យចុះហត្ថលេខាលើលិខិតដែលមានចំណងជើងថា "formal undertaking" ដើម្បីផ្លាស់ប្តូរនៅថ្ងៃទី 30 ខែមិថុនា និងការផ្លាស់ប្តូរជំហ៊ានបន្ទាប់ក្នុងរយៈពេលពីរឆ្នាំបន្ទាប់ទៀត។

អ្នកស៊ើបអង្កេតលើព័ត៌មានក្រុម ICO បានរកឃើញថា privacy policy អនុវត្តដោយក្រុមហ៊ុន Google កាលពីខែមីនា ឆ្នាំ 2012 ដែលក្នុងនោះមាន privacy policies ចំនួន 70 ត្រូវបានយកមកប្រើប្រាស់រួមហើយទិន្នន័យត្រូវបានប្រមូលផ្តុំតែមួយទាំងលើសេវាកម្ម YouTube, Gmail និង Google+ ផ្ទាល់។

ក្នុងនោះប្រទេសអេស្ប៉ាញ និងបារាំងពិន័យទឹកប្រាក់ប្រមាណ 1.02 រយលានដុល្លារលើ privacy policy លើក្រុមហ៊ុន Google។ នេះបញ្ជាក់ថាការគ្រប់គ្រងលើបណ្តាញ privacy policy របស់ក្រុមហ៊ុន Google នៅមានកម្រិត ដែលជាកត្តាជំរុញក្នុងការផ្លាស់ប្តូរការប្រើប្រាស់ privacy policy រួមគ្នា៕

# ក្តាចុចសមត្ថភាពខ្ពស់ សក្តិសមជាមួយអ្នករចនា Graphic



Keyboard សម្រាប់កុំព្យូទ័រសម័យនេះមានការប្រែប្រួលច្រើនទាំងការភ្ជាប់បច្ចេកវិទ្យា និងសមត្ថភាពផ្លាស់ប្តូរគួរឱ្យកត់សម្គាល់។

Jaasta E-Ink ជា Keyboard ដែលមានសមត្ថភាពខ្ពស់ អ្នកអាចប្រើ shortcut និងប៊ូតុងមួយចំនួនដើម្បីធ្វើការលើ Photoshop។ កាន់តែគួរឱ្យចាប់អារម្មណ៍លក្ខណៈ e-ink អាចមានសមត្ថភាពប្រើជាប្រភេទ wireless ភ្ជាប់ប្រើជាមួយឧបករណ៍មានចំងាយឆ្ងាយបាន។ Keyboard នេះមានទំហំ 3.7- អ៊ីង មានបំពាក់ touchpad ប្រើមុខងារ multi-touch បញ្ហាបានដូចលើអេក្រង់។ កាន់តែពិសេសជាងនេះទៅទៀតលើ Keyboard មានមុខងារគ្រប់គ្រងប្រព័ន្ធសម្លេង និងមុខងារ saving delete send និង search រកឯកសារក្នុងកុំព្យូទ័របានងាយស្រួល។

Jaasta keyboard មានដំណើរការដោយឯករាជ្យ មានប្រព័ន្ធ input ដំណើរការបាន 12 ខែ និងមានទំហំ 391 x 150 mm ងាយស្រួលយកតាមខ្លួន ៕

# ឧបករណ៍អេឡិចត្រូនិចជំនួយ Accessories

## កាន់តែមានភាពងាយស្រួលជាមួយ Mouse អត់ខ្សែ M510




កាន់តែមានភាពងាយស្រួលជាមួយ mouse ប្រភេទ Logitech M510 Wireless ដែលត្រូវបានផលិតចេញពីជ័រទន់ម៉្យាងមានរាងស្រស់ស្អាតសក្តិសមទៅនឹងដៃ និងការប៉ះកាន់របស់អ្នកប្រើប្រាស់ ។ នៅផ្នែកចំហៀងនៃ mouse មានប៊ូតុង 2 អនុញ្ញាតិឲ្យលោកអ្នកអាចធ្វើការអូសចុះឡើងពង្រីក ឬបង្រួម ដោយគ្រាន់តែប្រើប្រាស់តែម្រាមដៃមួយតែប៉ុណ្ណោះ។ រីករាយជាមួយ cursor ដែលមានភាពរលូនគ្មានភាពរអាក់រអួល និងថ្មដែលអាចប្រើប្រាស់បានរហូតដល់ទៅ 2 ឆ្នាំ តែនៅក្នុងលក្ខខ័ណ្ឌខ្លះគឺវាអាស្រ័យទៅនឹងអ្នកប្រើប្រាស់ ឬស្ថានភាពរបស់កុំព្យូទ័រផងដែរ។ ប្រើប្រាស់ជាមួយនឹងឧបករណ៍នេះអ្នកគ្រាន់តែដោត Logitech Unifying (ជា USB មួយប្រភេទដែលមានរាងតូច) ទៅកាន់កុំព្យូទ័ររបស់អ្នកដោយមិនចាំបាច់ប្រើប្រាស់ខ្សែឡើយ ៕



# SwissGear
## ដៃគូររបស់ Laptops ទំហំ 15.6-Inch



កាបូបស្ពាយម៉ាក SwissGear បង្កើតឡើងជាមួយនឹងរាងដ៏ស្រស់ស្អាត និងទាន់សម័យ។ កាបូបនេះត្រូវបានបង្កើតឡើងសម្រាប់ភាពងាយស្រួល និងមានមុខងារប្រើប្រាស់ជាច្រើន។ ទន្ទឹមនឹងនេះ វាមានដាក់បញ្ចូលនូវលក្ខណៈពិសេសៗ និងមានថតជាច្រើនសម្រាប់ផ្ទុកសមាសធាតុផ្សេងៗផងដែរ។ កាបូបស្ពាយប្រភេទនេះអាចផ្ទុកបានសម្ភារៈជាច្រើនដូចជាកុំព្យូទ័រ ឧបករណ៍លេងហ្គេម និងឧបករណ៍ផ្សេងៗទៀតរបស់កុំព្យូទ័រ។ លក្ខណៈដ៏ពិសេសបំផុតនោះគឺវាមានទំហំដែលត្រូវនឹងស្មារបស់មនុស្សទូទៅ និងមានប្រព័ន្ធ airflow ដែលបង្កើតនូវចរន្តខ្យល់ធ្វើឲ្យខ្នងរបស់អ្នកមានផាសុខភាព។ កាបូបស្ពាយដ៏អស្ចារ្យនេះ រៀបចំឡើងចេញជាថតដាច់ដោយឡែកពីគ្នាដែលអាចឲ្យអ្នកដាក់ប៊ិច ខ្មៅដៃ ស្មាតហ្វូន និងឧបករណ៍ផ្សេងទៀតដែលអ្នកត្រូវការ។ វាក៏មាននូវថតដែលអាចឲ្យអ្នកដាក់ដបទឹកបាន ហើយនៅលើផ្នែកនៃស្មាស្ពាយមានថតមួយសម្រាប់ឲ្យអ្នកដាក់វ៉ែនតារបស់អ្នកបានដូចគ្នាដែរ ៕



# ក្តារចុច Multi-Touch Touchpad អត់ខ្សែថ្មី K400




ឧបករណ៍ Logitech Wireless Touch Keyboard K400 គឺជាឧបករណ៍ថ្មីដែលមានភាពងាយស្រួល និងល្អបំផុតសម្រាប់ការក្នុងការវាយអត្ថបទ ឬក៏ការបញ្ជាដែលវាមាន keyboard បង្ហាញនូវតួអក្សរយ៉ាងច្បាស់ធ្វើឲ្យលោកអ្នកងាយស្រួលក្នុងការអានតួអក្សរនីមួយៗផងដែរ។ keyboard នេះមាន touch pad ទំហំ 3.5-inch មានដំណើរការដោយប្រព័ន្ធ multi-touch ល្អបំផុតសម្រាប់ការភ្ជាប់ទៅកាន់ web browser ផ្សេងៗ។ ភាពដ៏ប្រសើរបំផុតនោះលោកអ្នកអាចភ្ជាប់ទៅកាន់ laptop របស់អ្នកបាន និងអាចបញ្ជាទៅកាន់ស្មាត TV បាន ដែលវាអាចចាប់រលកសញ្ញាបានក្នុងរយៈចម្ងាយ 10m ឯណោះ ដោយអ្នកគ្រាន់តែដោត Logitech Unifying ( ជា USB មួយប្រភេទដែលមានរាងតូច ) បញ្ចូលក្នុង USB port របស់កុំព្យូទ័ររបស់លោកអ្នក និងធ្វើការតភ្ជាប់តាមរយៈផ្ទាំងបង្ហាញនៅក្នុង web browser យ៉ាងងាយស្រួលបំផុត។ ឧបករណ៍នេះ ដំណើរការជាមួយនឹងប្រព័ន្ធប្រតិបត្តិការប្រភេទ Windows 7 ប្រព័ន្ធ Windows Vista និងប្រព័ន្ធ Windows XP ផងដែរ ៕





## អាចធ្វើការថតសម្លេងជាមួយ

# USB Drive Voice Recorder

នេះគឺជាឧបករណ៍ដ៏តូចមួយតែមានប្រយោជន៍ ពោលគឺវាមានសមត្ថភាពក្នុងការថតយកសម្លេងពីការសន្ទនានៅក្នុងអង្គប្រជុំកិច្ចពិភាក្សា កិច្ចព្រមព្រៀងនៅក្នុងជំនួញ ឬក៏ជាសម្លេងផ្សេងៗ ទៀតដែលអ្នកចង់រក្សាទុក។ ឧបករណ៍នេះមានទំហំផ្ទុក 8GB និងផ្តល់នូវគុណភាពសម្លេងច្បាស់ ចំពោះសម្លេងដែលអ្នកបានថតរួច។ វាជា USB ដែលមានភាពងាយស្រួលក្នុងការប្រើប្រាស់ដោយអ្នកគ្រាន់តែដោតវាទៅកាន់កុំព្យូទ័ររបស់អ្នកនោះអ្នកនឹងអាចស្តាប់សម្លេង Record បានមិនចាំបាច់ត្រូវការ drivers បន្ថែមទៀតនោះទេ។ លោកអ្នកអាចគ្រាន់តែធ្វើការបញ្ចូលថាមពលរយៈពេល 2 ម៉ោង នោះលោកអ្នកនឹងអាចយកទៅប្រើប្រាស់បានរហូតដល់ 16 ម៉ោង។ USB នេះមានប៊ូតុងមួយនៅផ្នែកចំហៀង ប្រសិនបើអ្នកទាញវាទៅកាន់ទីតាំងពាក្យ ‘ON’ នោះវានឹងដំណើរការថតយកនូវសម្លេង តែបើស្ថិតនៅទីតាំងពាក្យ ‘OFF’ វានឹងបញ្ឈប់នូវការថតសម្លេង។ រាល់ file records ទាំងឡាយនៅក្នុង USB នេះជា file ដែលស្ថិតក្នុងប្រភេទ WAV ជា file ដែលងាយស្រួលក្នុងចាក់បំផុត៕





# កាសស្តាប់ H800 ជម្រើសថ្មីសម្រាប់ កុំព្យូទ័រ ស្មាតហ្វូន និង Tablets







នេះគឺជាកាសស្តាប់ត្រចៀកដែលអាចប្រើប្រាស់ជាមួយនឹងកុំព្យូទ័រ ជាមួយស្មាតហ្វូន និងជាមួយ tablet ហើយងាយស្រួលក្នុងការតភ្ជាប់បំផុត។ កាសនេះផ្តល់សម្លេងច្បាស់ និងធំ ពីព្រោះវាមានបំពាក់ដោយប្រព័ន្ធ Laser-tuned speaker ដែលវាមានមុខងារក្នុងការរក្សានូវលំនឹងរបស់សម្លេង ជាពិសេសនោះគឺវាជួយកាត់បន្ថយនូវរាល់សម្លេងរំខានធ្វើឲ្យសម្លេងច្បាស់ក្នុងខណៈពេល call ឬស្តាប់តន្ត្រីជាដើមនោះ។ កាសស្តាប់ H800 ប្រើប្រាស់ប្រព័ន្ធ Bluetooth ដើម្បីធ្វើការតភ្ជាប់ទៅរាល់ឧបករណ៍ផ្សេងទៀតបានស្ថិតក្នុងរយៈចម្ងាយរហូតដល់ទៅ 12m ឯណោះ ។ ម៉្យាងវិញទៀតវាមានបំពាក់ទៅដោយថ្មមួយប្រភេទដែលអាចឲ្យអ្នកបន្តប្រើប្រាស់បានរហូតដល់ទៅ 6 ម៉ោង ហើយអាចបញ្ចូលថាមពលវិញដោយប្រើប្រាស់ USB ដ៏តូចមួយ។ ចំណុចដែលគួរឲ្យកត់សម្គាល់នោះ គឺឧបករណ៍នេះត្រូវបានរចនាឡើងជារូបរាងដ៏ស្រស់ស្អាត និងមានផាសុខភាពសម្រាប់ត្រចៀករបស់អ្នក ៕

Computer Review

# Asus G751 Series

## កុំព្យូទ័រហ្គេមជំនាន់ថ្មី




ក្រុមហ៊ុន Asus បានផលិតកុំព្យូទ័រហ្គេមថ្មីៗជាច្រើន ជាពិសេសកុំព្យូទ័រទាំងនោះផ្លាស់ប្តូរការរចនាកាន់តែប្លែក ចាប់ចិត្តគួយឱ្យចង់ប្រើ។ G751 SERIES ជាកុំព្យូទ័រហ្គេមរចនាមកមានរូបរាងកាន់តែទាក់ទាញរូបរាងមាំធន់ ជាពិសេសការបំពាក់សមត្ថភាពថ្មីត្រូវបានបន្ថែម ។ ការ រចនានេះទៀតសោតត្រូវបានធ្វើឡើងដោយក្រុម Republic Of Grammar។ គំនិតច្នៃប្រឌិតលើរូបរាងបូកផ្សំ នឹងការលេងម៉ូតគែមបន្ថែមធ្វើឱ្យម៉ូដែលថ្មីនេះកាន់តែពិសេសទ្វេរដង ។



Computer Review



ក្រលេកឃើញភ្លាមអ្នកនឹងដឹងថាម៉ូដែលនេះមានតែមថ្មីព័ទ្ធអេក្រង់កាន់តែស្រស់ស្អាត។ ម៉ូដែល G751 SERIES ប្រើប្រាស់អង្គដំណើរការប្រភេទ Intel@ Core TM i7-4860HQ processor។ ដំណើរការខាងក្នុងល្អដោយភ្ជាប់បន្ថែមជាមួយប្រព័ន្ធ NVIDA@ GeForce @GTX 980M ទំហំ 4GB។ គុណភាពម៉ូដែល នេះកាន់តែខ្ពស់ 6X Blu-ray Burner ។ ផ្នែក ខាងនៃកុំព្យូទ័រនេះមាន 4So-DIMM slots support បានអង្គចងចាំទំហំ 32GB (RAM) ។



ផ្នែក Keyboard កាន់តែពិសេសបំពាក់គ្រាប់ប៊ូតុងទន់ងាយស្រួលប្រើជាមួយមុខងារបញ្ជា Shortcut ផ្សេងទៀតៗ។ អ្នកទទួលបានអារម្មណ៍ថ្មីជាមួយនឹងដំណើរការប្រើប្រាស់ Key លឿនដើម្បីចូលទៅ Steam និងកំណត់ហ្គេមប្រើប្រព័ន្ធ Tap កាន់តែងាយស្រួលបញ្ជាជាមួយនឹងល្បឿនលឿនគ្មានបញ្ហា ។

ម៉ាស៊ីនរបស់អ្នកនឹងមិនក្តៅពេលប្រើប្រាស់យូរប៉ុណ្ណោ ដោយសារតែមាន Daul Fans ធ្វើឱ្យកម្តៅកុំព្យូទ័ររបស់អ្នកថយចុះ។ បច្ចេកវិទ្យាថ្មីមួយទៀតប្រើដើម្បីកាត់បន្ថយ Boost បានបរិមាណ 5% ដោយ GPU TurboMaster ល្អជាងមុន ។






កាន់តែពិសេសក្រាហ្វិករបស់វាខ្លាំងអួសរូបភាពបានល្អបុកផ្សំនឹងកម្រិតភិចសែលច្បាស់ត្រជាក់ភ្នែក។ មួយវិញទៀតគុណភាពសម្លេងខ្លាំងប្រើ Audio កម្រិតថ្មីដោយភ្ជាប់បច្ចេកវិទ្យា ROG AudioWizard ខ្លាំងជំនួយសម្លេងច្បាស់ល្អ ។

## លក្ខណៈទូទៅ

**Processor** 2.5 GHz Intel Core i7-4710HQ Quad-Core 4th-Gen Haswell
**Processor Turbo Speed**3.5GHz
**Cache** L3: 6 MB
**Memory** Type: DDR3L SDRAM
Installed: 24 GB
Capacity: 32 GB
**Graphics Card** Type: Dedicated
Installed: NVIDIA GeForce GTX 980M with 4 GB GDDR5 SDRAM Dedicated
**Screen Type** Widescreen
**Screen Size** 17.3"
**Backlight** LED
**Aspect Ratio** 16:9
**Finish** Antiglare
**Native Resolution** 1920 x 1080
**Hard Drive** Installed: 1.256TB(1x 1TB7200 rpm; 1x 256 GB SSD)
Type: SATA
**Optical Drive** Blu-ray Burner

# Lenovo Yoga 3 pro

## ស្តើង បត់បែនតាមតម្រូវការ

ក្រុមហ៊ុន Lonevo ទទួលបានឈ្មោះល្បីល្បាញយ៉ាងខ្លាំងក្នុងការផលិត ហើយរាល់ផលិតផលពេលនេះទទួលបានការពេញនិយមយ៉ាងខ្លាំងមិនចាញ់ក្រុមហ៊ុនខ្លាំងៗមួយចំនួនផ្សេងទៀត។ ថ្មីៗនេះក្រុមហ៊ុនផលិតបានកុំព្យូទ័រ YoGa 3 Pro រចនាឡើងមានរូបរាងស្រស់ស្អាត និងតូច ស្តើងគួរឱ្យចាប់ចិត្តលើផ្ទៃអេក្រង់ធំទូលាយ និងអាចបត់បានងាយស្រួលប្រើប្រាស់តាមកាលៈទេសៈ។ ម្យ៉ាងទៀត ម៉ូដែលថ្មីនេះជាប្រភេទកុំព្យូទ័រយួរដៃដែលមានកម្រាស់ស្តើងបំផុតត្រឹមតែ 0.50" មិនធ្លាប់មានពីមុនមក។







អ្វីដែលជាចំណុចគួរឱ្យចាប់ចិត្តបំផុតម៉ូដែល YoGa 3 Pro ជាប្រភេទកុំព្យូទ័រដែលប្រើបត់បាន ដោយអាចបត់ KeyBoard ឱ្យទល់ខ្នងជាមួយ អេក្រង់បង្ហាញ ងាយស្រួលសម្រាប់អ្នកប្រើប្រាស់ មើលវីដេអូ ឬមើលកិច្ចការផ្សេងៗដោយមិនចាំបាច់លាត KEYBOARD នាំឱ្យទើសនោះទេ។ លក្ខណៈនៃការបត់នោះទៀតសោត ចំណុចភ្ជាប់របស់ត្រូវបានរចនាឡើងដូចចំណុចចាប់របស់ខ្សែនាឡិការដៃ ហេតុដូច្នេះអ្នកអាចបត់ទៅមកដោយមិនចាំបាច់ភ័យព្រួយបាក់បែក។ រូបរាងគួរឱ្យចាប់ចិត្តបន្ថែមជាមួយនឹងការរចនាមានគែមកោង និងការស្រោបជុំវិញដើម្បីកាត់បន្ថយភាពកោសឆូត និងការពារគុណភាពប្រើប្រាស់ឱ្យបានកាន់តែយូរ ។

អ្នកនឹងទទួលបានបទពិសោធន៍ថ្មី ក្នុងការប្រើប្រាស់ ក្រៅពីមុខងារបត់បាន អ្នកអាចប៉ះបញ្ជាដោយផ្ទាល់លើអេក្រង់ប្រភេទ 13.3" QHD+ 3200 x 1800 IPS (multitouch display ) ដោយឯករាជ្យមិនចាំបាច់រកជើងទល់ និងឧបករណ៍ជំនួយផ្សេងៗទៀតទេ។ ម្រាមទាំងដប់របស់អ្នកអាចប្រើប៉ះបញ្ជាទាញចេញចូលផ្លាស់ប្តូរចលនាលើអេក្រង់ដូចកំពុងកាន់ឧបករណ៍ Tablet មួយក្នុងដៃដោយពុំចាំបាច់លាត Keyboard ចេញមក។ ពិសេសជាងនេះទៅទៀតគ្រាន់តែបត់ Keyboard មកវិញអ្នកនឹងទទួលបានកុំព្យូទ័រយួរដៃមួយដែលមានមុខងារច្រើនរាប់មិនអស់សម្រាប់ធ្វើការដោយប្រើ keyboard ។

លើអេក្រង់យ៉ាងធំទូលាយអ្នកអាចធ្វើការប៉ះលើអេក្រង់ QHD+ TOUCHSCREEN DISPLAY ដែលមានកម្រិតបង្ហាញខ្ពស់ (3200x 1800) ។ នៅពេលវាមានមុខងារជា កុំព្យូទ័រយួរដៃនោះ អ្នកគ្រាន់តែបត់ KEYBOARD ឡើងមកវិញ និងធ្វើការងារទូរទៅបានស្រួលដូចកុំព្យូទ័រទូរទៅ។ កុំព្យូទ័រនេះមានកម្លាំងខ្លាំងដោយសារប្រព័ន្ធអង្គដំណើរការ Intel® Core™ M-70 (processor) សក្តិសមជាមួយនឹងប្រព័ន្ធដំណើរការ Windows 8.1 Pro ធ្វើឱ្យប្រព័ន្ធកម្មវិធីរត់ស្រួល និង Support ជាមួយកម្មវិធីទំនើបៗជាច្រើន។ ក្រៅពីមុខងារចំរុះ និងភ្ជាប់ប្រព័ន្ធដំណើរការខ្លាំងម៉ូដែលនេះប្រើប្រាស់ថ្មដែលមានថាមពលរហូតដល់ទៅ 7.2 ម៉ោង ។



## លក្ខណៈទូទៅ

**Processor**
Intel® Core™ M-70 processor
**Operating System**
Up to Windows 8.1 Pro
**Size & Weight**
11.8 x 9 x 0.5 ~2.6 lbs
**Hinge**
6-hinge watchband design
**Display**
13.3" QHD+ 3200 x 1800 IPS multitouch
**Battery Life**
Up to 7.2 hours*
**Audio**
JBL® speakers with Waves Audio

# Dell Inspiron Small 3000 Series

## រូបរាងថ្មី ប្រកបដោយផាសុកភាព






ក្រុមហ៊ុន Dell មានឈ្មោះបោះសម្លេងខ្លាំង និងទទួលបានការគាំទ្រយ៉ាងច្រើនពីសំណាក់អ្នកប្រើប្រាស់កុំព្យូទ័រតាមបណ្តាសាកលលោក។ ពេលនេះ PC ថ្មីមានគុណភាព និងការបំពាក់ រួមជាមួយសមត្ថភាពភ្ជាប់ពិសេសជាងមុន។ Inspiron ភ្ជាប់ធុងដែលត្រូវបានរចនាឡើងមានរូបរាងស្រស់ស្អាត ងាយស្រួលដាក់ជាមួយទីតាំងលើតុ ឬនៅកៀនណាមួយដែលមានចន្លោះតូច។ អ្នកអាចអោប ឬលើកបានកាន់តែងាយស្រួលជាងធុងកុំព្យូទ័រមុន ហើយមិនខ្លាចទើស ឬចង្អៀតកន្លែងធ្វើការនោះទេ ។



PC តូចមួយនេះក្រៅពីមានរូបរាងស្រស់ស្អាត វាថែមទាំងភ្ជាប់ប្រព័ន្ធដំណើរការជំនាន់ទី4 ប្រភេទ Gen Intel® Core™ i5 (processors) មានសមត្ថភាពខ្លាំងដំណើរការបានល្អ។ យ៉ាងណា PC តូចនេះ ផ្តល់ថាសផ្ទុកទិន្នន័យរហូតដល់ទៅទំហំ 1 TB សម្រាប់ឱ្យអ្នកប្រើប្រាស់រក្សាទិន្នន័យបានកាន់តែច្រើន។ ទោះបីជា PC នេះមានរូបរាងតូច ប៉ុន្តែវាមានសមត្ថភាពដំណើរការជាមួយកម្មវិធីបានច្រើនប្រភេទ ទោះបីជាអ្នកប្រើប្រាស់ដើម្បីគ្រប់គ្រងវិបសាយ បង្កើតវីដេអូ ចាក់រឿង បទចំរៀង បានទាំងអស់។ ក្រៅពីប្រព័ន្ធថាមពលខ្លាំងម៉្យាងដែលនេះប្រើប្រាស់ប្រព័ន្ធដំណើរការប្រភេទ Windows 8.1 និងពិសេសជាងនេះទៅទៀតអ្នកអាចជ្រើសរើសប្រើ Windows® 7 លើ Option មានស្រាប់ក៏បាន ។

ទោះបីជា PC ថ្មីមានរាងតូច ប៉ុន្តែមុខងារច្រើនយ៉ាងមានមិនខុសពីធុងធំៗនោះទេ។ ផ្នែកផត សម្រាប់ភ្ជាប់ពី PC នេះទៅឧបករណ៍ផ្សេងទៀត មានដូចជា ផត USB 3.0 USB 2.0 កាត 8-in-1 នៅផ្នែកខាងសម្រាប់ភ្ជាប់ជួរលើបំផុតមានរន្ធដោតកាសចំនួនបី support 5.1 សម្លេងឮច្បាស់មិនបែក។ សម្រាប់ផត USB 2.0 មានចំនួន 06 និងផត USB 3.0 មានចំនួន 02 ដែលអ្នកអាចប្រើសម្រាប់ចម្លងទិន្នន័យបានលឿន។ VGA output នៅក្រោមបន្ទាប់នោះអ្នកអាចប្រើភ្ជាប់ជាមួយឧបករណ៍ Projector ផ្សេងៗទៀតបានដោយទំហំរបស់វាមិនតូចដូចធុងទេ ។



ផ្នែក Dropbox លើ PC នេះ អ្នកអាចចូល Edit និង share រូបភាព និងបើកវីដេអូបានគ្រប់ទីកន្លែង។ ទោះបីជា PC របស់អ្នកជួបបញ្ហាក៏ឯកសារក្នុង Dropbox មានសុវត្ថិភាព។ ការផ្តល់ជូនពិសេសមួយគឺនៅពេលដែលអ្នកទិញ PC របស់ Dell ម៉ាកថ្មីនេះភ្លាមអ្នកនឹងអាចទទួលបានទំហំផ្ទុកទិន្នន័យ 20GB បន្ថែមទៀត ៕

Dropbox



## លក្ខណៈទូទៅ

**Processor**
Intel® Celeron® Processor J1800 (1M Cache, up to 2.58 GHz)

**Operating System**
Windows® 8.1 with Bing

**Memory2**
4GB Single Channel DDR3L 1600MHz (4GBx1)

**Hard Drive3**
500GB 7200 rpm Hard Drive

**Video Card4**
Intel® HD Graphics

**Optical Drive**
Tray load DVD Drive (Reads and Writes to DVD/CD)

**Keyboard**
Dell USB Wired Entry Keyboard KB113

**Standard Wired Mouse**
Dell USB Optical Mouse

# Thinkcentre E63z

## កាន់តែសម្បូរបែប និងស៊ីវីល័យ

ThinkCentre E63z ម៉ូដែលថ្មី និងចុងក្រោយបង្អស់រចនាមកតម្រូវការប្រើប្រាស់ទូទៅរបស់មនុស្សជំនាន់ថ្មីឱ្យកាន់តែសម្បូរបែប និងស៊ីវីល័យ។ វាត្រូវបានរចនាមកជាមួយរូបរាងស្រស់ស្អាត និងទាក់ទាញជាមួយនឹងការបំពាក់អេក្រង់ទំនើបមានទំហំធំទូលាយងាយស្រួលចុចបញ្ជា ហើយម៉្យាងទៀត ThinkCentre E63z មានកម្រាស់ត្រឹមតែ 37.5 mm ងាយស្រួលទុកដាក់យកតាមខ្លួន។ ម៉្យាងទៀត វាត្រូវបានគេបំពាក់ជើងបញ្ឈរដែលមានមុខងារទ្រ និងទប់លំនឹងឱ្យកាន់តែពិសេសសម្រាប់អ្នកក្នុងការមើល YouTube និងវីដេអូផ្សេងៗដោយឯករាជ្យ។ ទំហំស្តង់ដាគួរឱ្យចាប់ចិត្តជាមួយនឹងអេក្រង់ទំហំ 19.5 ទម្ងន់ទំហំទាំងបី 488mm x 346mm x 62mm (19.2" x 13.6" x 2.4") ហើយថែមទាំងបានច្របាច់បញ្ចូល 3W stereo សម្រាប់បំពងសម្លេងឲ្យកាន់តែពិរោះរណ្តំចិត្តទៀតផង។






ក្នុងការប្រើប្រាស់ម្រាមទាំងដប់របស់អ្នកប្រើដើម្បីវាស រុញចុះឡើងតាមចិត្តលើផ្ទៃអេក្រង់ មិនត្រឹមតែប៉ុណ្ណោះអ្នកថែមទាំងអាចប្រើការវិការដើម្បីគ្រប់គ្រងបញ្ហាបានថែមទៀតផង។ កាន់តែពិសេសបន្ថែមទៀតនោះ ម៉ូដែលនេះត្រូវបានភ្ជាប់ការបង្ហាញប្រភេទ multiple ដែលការប្រើប្រាស់ពុំមានលក្ខណៈប៉ះពាល់ដល់កម្មវិធី ហើយថែមបញ្ហាគាំង ទោះបីជាអ្នកប្រើប្រាស់ multiple displays ក៏ដោយ។

កាន់តែពិសេស ThinkCentre E63z មានតួនាទីចែកចាយឯកសារផងដែរ ជាមួយផត USB ដែលមានសមត្ថភាពភ្ជាប់ទៅកាន់ PC របស់អ្នក ហើយថែមទាំងមានសុវត្ថិភាពការពារទិន្នន័យពីចោរ និងការវាយប្រហារលើបណ្តាញដែលជារឿងវិលមុខបំផុតនាពេលបច្ចុប្បន្ននេះ។ Smart USB ជាផតដែលប្រើភ្ជាប់ជាមួយ keyboard និង mouse ប៉ុន្តែអ្នកមិនអាចចម្លងឯកសារទៅកាន់ USB drive បានទេ។ មួយវិញទៀត USB 3.0 មានល្បឿនលឿនជាងបច្ចេកវិទ្យា USB មុនៗដល់ទៅដប់ដង។ USB 3.0 SuperSpeed ថែមទាំងមានសមត្ថភាពបញ្ជូនទិន្នន័យពី PC ទៅកាន់ឧបករណ៍ផ្សេងទៀតលឿន និងមិនបណ្តាលឱ្យបាត់បង់ទិន្នន័យឡើយ។

ThinkCentre E63z ប្រើកម្លាំង ENERGY STAR និង GREENGUARD-compliant រួម EPEAT® Silver ដែលប្រើថាមពលតិចបំផុត ជាពិសេសបើអ្នកប្រើភ្ជាប់ជាមួយ Desktop របស់ក្រុមហ៊ុន Lenovo ការប្រើប្រាស់ថាមពលកាន់តែតិច ហើយកម្លាំងកាន់តែខ្លាំង ៕






## លក្ខណៈទូទៅ

**Processor**
Intel® Pentium® Processor J2900
**Operating System**
Windows 8.1 Pro 64 bit
**Graphics**
Intel® HD Graphics Integrated
**Memory**
Maximum 8GB 1 x DIMM, SO-DIMM DDR3L-1333
**Storage**
Up to 1TB 2.5" HDD, up to 500GB 2.5" SSHD
Up to 256GB 2.5" OPAL SSD
**Webcam**
1MP Webcam with digital mic (optional) for ROW
2MP for PRC only
**Display**
19.5" WLED HD+ 1600 x 900 (16:9) with 10-point multitouch
**Dimensions (W x D x H)**
Without Package: 13.62" x 2.44" x 19.21" (346 mm x 62 mm x 488 mm)
With Package: 17.67" x 5.51" x 23.22" (449 mm x 140 mm x 590 mm)




# GEFORCE GTX 980

## សមត្ថភាពខ្លាំង ពិសេសល្អបំផុតសម្រាប់លេងហ្គេម

ជាមួយនឹងក្រាហ្វិក GEFORCE GTX 980 ជំនាន់ថ្មីនេះ បានភ្ជាប់មកជាមួយនឹង MSI Twin Frozr ដែលធ្វើឲ្យសំឡេងស្ងាត់ និងកាត់បន្ថយកំដៅបានយ៉ាងល្អ។ Twin Frozr V មានរាងតូចភ្ជាប់ជាមួយនឹងកង្ហារដែលមានកម្លាំងខ្លាំងធ្វើឲ្យម៉ាស៊ីនទាំងមូលមានភាពត្រជាក់ដែលសក្តិសមបំផុតជាមួយនឹង MSI Gaming Motherboard ដែលមានដូចជា LED Lightning ។






មិនត្រឹមតែប៉ុណ្ណោះ Twin Frozr នេះអាចកាត់បន្ថយភាពត្រជាក់ដល់ទៅ 17% ដែលខ្លាំងជាង GTX 770 ដែលកាត់បន្ថយបានត្រឹមតែ 12% តែប៉ុណ្ណោះ។ កង្ហាររបស់ក្រាហ្វិកកាតនេះអាចធ្វើឲ្យកម្លាំងខ្យល់បក់ដល់ទៅ 19% ដែលធ្វើឲ្យម៉ាស៊ីនត្រជាក់នឹងសំឡេងស្ងាត់ល្អ។ SuperSU PIPE ប្រើប្រាស់នូវបន្ទះ Nickel Plated Copper ធ្វើឲ្យខ្យល់រត់បានពេញក្រាហ្វិកនេះ។

MSI Hybrid Frozr គឺជាកង្ហារត្រជាក់ដែលមានពីរផ្នែកសំខាន់ៗគឺ Zero Frozr ដែលជួយកាត់បន្ថយកំដៅម៉ាស៊ីន និង Independent Fan Control សម្រាប់ធ្វើការគ្រប់គ្រងនៅលើប្រព័ន្ធខ្យល់ដែលរត់កាត់ក្រាហ្វិកកាតនេះទាំងមូលតែម្តង។ GEFORCE GTX 980 ស៊េរីថ្មីនេះថែមទាំងប្រើប្រាស់ជាមួយនឹងបច្ចេកវិទ្យា Scenamax ដែលផ្តល់នូវភាពងាយស្រួលក្នុងការដំណើរការជាមួយនឹងរូបភាពដែលមានកម្រិតខ្ពស់ និងផ្តល់នូវដំណើរការលឿនសម្រាប់អ្នកដែលចូលចិត្តលេងហ្គេមដែលមានក្រាហ្វិកធំនោះ ៕

**លក្ខណៈពិសេស ៖**

| | |
|---|---|
| Graphics Processing Unit | NVIDIA Geforce GTX 980 |
| Interface | PCI Express x16 3.0 |
| Core Clock Speed (MHz) | |
| 1216MHz Core (Boost Clock:1317MHz) (OC Mode) | |
| 1190MHz Core (Boost Clock:1291MHz) (Gaming Mode) | |
| 1127MHz Core (Boost Clock:1216MHz) (Silent Mode) | |
| Memory Size (MB) | 4096 |
| Memory Type | GDDR5 |
| Memory Interface | 256 bits |
| Memory Clock Speed (MHz) | 7010 |
| DVI Connectors | 1 (Dual-link DVI-I) |
| Max Resolution | 2560 x 1600 @60 Hz |
| HDMI Connectors | 1 (version 1.4a/2.0) |

| | |
|---|---|
| Max Resolution: | 4096x2160 @24 Hz (1.4a), 3840x2160 @60 Hz (2.0) |
| DisplayPort | 3 (version 1.2) |
| Max Resolution | 4096x2160 @60 Hz |
| Maximum Displays | 4 |
| RAMDAC speed (MHz) | 400 |
| Multi-GPU Technology | SLI, 4-way |
| Card Dimension(mm) | 279 x 140 x 36 |
| Card Weight (g) | 936 |
| Power consumption | 165 (W) |
| Power Connectors | 8-pin x 2 |
| Accessories | 1 x 8-pin Power Cable, 1 x DVI to VGA Dongle |




# SAPPHIRE R9 290 4GB GDDR5

## រូបរាងថ្មីទាន់សម័យ សមត្ថភាពកាន់តែខ្ពស់

ដើម្បីបង្កើននូវដំណើរកាន់តែលឿន កាត់បន្ថយកំដៅ និងរក្សាល្បឿននៃអង្គប្រតិបត្តិការកុំឲ្យដំណើការខ្លាំង ពេលនេះយើងសូមណែនាំនូវក្រាហ្វិកកាតស៊េរីថ្មីដែលមានការរចនារូបរាងយ៉ាងស្រស់ស្អាតនោះគឺ SAPPHIRE R9 290 4GB GDDR5 ។ ក្រាហ្វិកកាតនេះបានភ្ជាប់មកជាមួយនឹង 2560 Stream Processing Units និងមាន Engine Clock ដល់ទៅ 947Mhz ។

មិនត្រឹមតែប៉ុណ្ណោះ វាបានបំពាក់មកជាមួយនឹងមេម៉ូរីប្រភេទ GDDR5 ទំហំ 4GB ដែលមាន Interface 512 bit និងមាន Clock ទំហំខ្ពស់ដល់ទៅ 1250Mhz ដែលផ្តល់នូវ Bandwidth ដែលមានកម្រិតខ្ពស់ ព្រមទាំងទ្រទ្រង់នូវការដំណើរការហ្គេមកាន់តែលឿនជាមួយនឹងកម្រិតភាពច្បាស់ UltraHD Resolution ផងដែរ។

វាបានភ្ជាប់មកជាមួយនឹង HDMI (3D) អាចទ្រទ្រង់ជាមួយនឹង Deep Color, Birate Audio 7.1, 3D Stereoscopic និងអាចដំណើរការជាមួយនឹង Blu-ray ដែលមានកម្រិតខ្ពស់ផងដែរ។ GDDR5 ផ្តល់នូវ Bandwidth កម្រិតខ្ពស់ដែលផ្តល់នូវល្បឿនលឿន។ Dual-Link DVI-D សម្រាប់ដំណើរការបានយ៉ាងល្អជាមួយនឹង UltraHD ដែលមានកម្រិតខ្ពស់ដល់ទៅ 2560x1600។ មិនត្រឹមតែប៉ុណ្ណោះវាថែមទាំងភ្ជាប់ជាមួយនឹងបច្ចេកវិទ្យា AMD HD3D, AMD Stream, AMD Avivo HD, PCI Express 3.0 និង AMD Eyefinity 2.0 ផងដែរ ៕




## លក្ខណៈពិសេស៖

Display អាចទ្រទ្រង់បាន 3 Display Monitors ដោយគ្មាន DisplayPort

| | |
|---|---|
| Output | 1 x HDMI ( ជាមួយ 3D) |
| | 1 x DisplayPort 1.2 |
| | 2 x Dual-Link DVI-D |
| GPU | 947 MHz Core Clock |
| | 28 nm Chip |
| | 2560 x Stream Processors |

| | |
|---|---|
| Video Memory | 4096 MB |
| | 512 -bit GDDR5 |
| | 5000 MHz Effective |
| វិមាត្រ | 277(L)X104(W)X35(H) mm |
| Accessory | 8 PIN ទៅ 4 PIN Power Cable |
| | 6 PIN ទៅ 4 PIN Power Cable |
| | HDMI 1.4a ល្បឿនលឿនជាមួយនឹងខ្សែប្រវែង 1.8 ម៉ែត្រ |



# កម្មវិធីថ្មីៗ
# New Softwares



## MiniTool Power Data Recovery ជំនាញក្នុងការ Recovery ទិន្នន័យដែលបាត់បង់

MiniTool Power Data Recovery គឺជាកម្មវិធីសម្រាប់ធ្វើការ Recovery File ដែលមានទំហំតូច និងមានសមត្ថភាពខ្ពស់ជាមួយនឹង RAID Recovery ។ ការទាញ Recovery Files គឺជាកិច្ចការលំបាកប៉ុន្តែ ជាមួយនឹងកម្មវិធីនេះអាចប្រើប្រាស់បានជាមួយនឹង SSD ។ MiniTool Power Data Recovery មានសមត្ថភាពខ្ពស់ក្នុងការជួយលោកអ្នកក្នុងការទាញយកទិន្នន័យ Data Recovery នៅពេលដែលប្រព័ន្ធប្រតិបត្តិការរបស់លោកអ្នកត្រូវបានបំផ្លាញ ឬខូច៕




| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 62 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## Youtube Video Downloader
### អ្នកឯកទេសទាញយកវីដេអូ

Youtube Video Downloader ជាកម្មវិធីដែលមានការងាយស្រួលក្នុងការប្រើប្រាស់ និងត្រូវបានបង្កើតសម្រាប់ធ្វើការទាញយកការមើលវីដេអូពីវេបសាយដែលល្បីល្បាញដូចជា Youtube, Facebook, Google Video, Yahoo Video និងវេបសាយជាច្រើនទៀត។ មិនត្រឹមតែប៉ុណ្ណោះ Youtube Video Downloader អនុញ្ញាតិឲ្យអ្នកធ្វើការ Convert វីដេអូទៅជាទម្រង់ផ្សេងគ្នាដូចជា MP3, MP4, AVI, 3GP, MPEG ដែលអាចយកទៅបើកបាននៅលើឧបករណ៍ជាច្រើនដូចជា iPod, iPhone, PSP និង iTunes ជាដើម៕




| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 10 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## BlueStacks សមត្ថភាពខ្ពស់ដំណើរការកម្មវិធី Android

BlueStacks គឺជា Innovative Emulator ដែលអនុញ្ញាតិអាចឲ្យលោកអ្នកធ្វើការដំណើរការនូវកម្មវិធី ឬវីដេអូរបស់ទូរស័ព្ទ Android ដោយផ្ទាល់បាននៅលើអេក្រង់ Monitors Windows របស់អ្នក។ កម្មវិធីនេះជួយអ្នកអាចធ្វើការលេងហ្គេម Android នៅលើ PC Desktop ឬ Laptop ដោយមិនចាំបាច់ភ្ជាប់ទូរស័ព្ទរបស់អ្នកទៅកាន់ PC នោះទេ។ BlueStacks អាចដំណើរការកម្មវិធីនៅលើ Winodows ដែលផ្តល់នូវការទ្រទ្រង់ទៅគ្រប់កម្មវិធី Android Apps ជាពិសេសក្រាហ្វិក HD និងមានសមត្ថភាពក្នុងការ Sync និងធ្វើការ Backup Data និងកម្មវិធីសម្រាប់រក្សាទុកនៅលើកុំព្យូទ័ររបស់អ្នក៕




| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 272 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## MOBILedit Forensic អ្នកជំនាញកោសល្យវិច័យទិន្នន័យ




MOBILedit Forensic ជាកម្មវិធីធ្វើកោសល្យវិច័យដែលអាចប្រើប្រាស់បានជាមួយនឹងទូរស័ព្ទច្រើនប្រភេទដូចជា Samsung, HTC, Nokia, Sony, LG និង Motorola ។ ជាមួយនឹងកម្មវិធីនេះ អ្នកអាចធ្វើការទាញយកទិន្នន័យបានយ៉ាងងាយស្រួលបំផុត។ ទិន្នន័យដែលទាញយកមកនោះរួមមាន History, Phonebook, Text Messages, Multimedia Messages, Files, Calendars និង Notes ។ វាក៏ទាញទិន្នន័យដូចជា IMEI, OS, Firmware ដែលមានព័ត៌មានដូចជា IMSI, ICCID និង BTS ផងដែរ។ MOBILedit Forensic ជាកម្មវិធីពិសេសដែលអាចធ្វើការផ្តល់នូវ Reports ពីទិន្នន័យរបស់ជនសង្ស័យបានយ៉ាងមានប្រសិទ្ធិភាព៕

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 226 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## GForce Virtual String Machine អ្នកជំនាញគ្រប់គ្រងបទភ្លេង




GForce Virtual String Machine ជាកម្មវិធីដែលមាន Interface បែបសាមញ្ញ ប៉ុន្តែវាមានឥទ្ធិពលទៅលើ Virtual String Machine ដែលអាចធ្វើការផ្តិតនូវសំឡេងចេញពីឧបករណ៍ជាច្រើនប្រភេទ និងមានសមត្ថភាពខ្ពស់ក្នុងការកែសាច់ភ្លេងគ្រប់ចង្វាក់ផងដែរ។ ជាមួយនឹង VSM វាបានផ្តល់នូវ 17 Classic String, 66 Sample Sets និងមុខងារពិសេសៗជាច្រើនទៀត៕

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 4.5 GB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## Trojan Killer អ្នកឯកទេសកម្ចាត់មេរោគ Trojan




Trojan Killer ជាកម្មវិធីដែលកំពុងតែពេញនិយមក្នុងការកម្ចាត់មេរោគ Malwares ដែលមានដូចជា Viruses, Bots, Spyware, KeyLoggers, Trojans, Scareware, Rootkits ដែលលោកអ្នកមិនបាច់ចូលទៅកែប្រែនៅក្នុង System Files ឬ Registry នោះទេ។ Trojan Killer អាចធ្វើការស្កេនបាននូវប្រភេទ Files ជាច្រើនទៀតដូចជា Adware, Spyware, Remote Access Trojans, Internet Worms ជាដើម។ វាផ្តល់នូវសុវត្ថិភាពក្នុងមុខងារធ្វើយ៉ាងណាឲ្យកុំព្យូទ័ររបស់អ្នកមានការការពារខ្ពស់។ មិនត្រឹមតែប៉ុណ្ណោះ លោកអ្នកអាចធ្វើការ Update នូវកម្មវិធីនេះដើម្បីឲ្យវាស្គាល់នូវមេរោគថ្មីៗ ក៏ដូចជាទាញយក Features ថ្មីចុងក្រោយរបស់វាផងដែរ៕

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 67 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## Bitdefender Internet Security 2015 កំពូលអ្នកកម្ចាត់មេរោគ

Bitdefender Internet Security 2015 ជាកម្មវិធីកម្ចាត់មេរោគដែលមានសុវត្ថិភាពខ្ពស់ក្នុងការការពារនូវទិន្នន័យរបស់អ្នក ហើយវាថែមទាំងមានមុខងារជា Firewall ដ៏រឹងមាំផងដែរ។ កម្មវិធីនេះអាចកម្ចាត់មេរោគបានច្រើនប្រភេទព្រោះវាមានមុខងារ Antivirus និង Antispyware ។ Bitdefender Internet Security 2015 បំពាក់ជាមួយនឹងបច្ចេកវិទ្យាថ្មីដែលដំណើរការស្កេនមានល្បឿនលឿន ហើយវាថែមទាំងការពារការវាយប្រហារពី Internet Connections ក៏ដូចជាការការពារមេរោគនៅពេលដែលលោកអ្នកភ្ជាប់ជាមួយនឹង Wi-Fi Connections ផងដែរ។ លោកអ្នកនឹងមានការការពារខ្ពស់ ផ្តល់នូវសុវត្ថិភាពចំពោះទិន្នន័យរបស់លោកអ្នក ហើយផ្តល់នូវទំនុកចិត្តខ្ពស់ជាមួយនឹងកម្មវិធី Bitdefender Internet Security 2015 នេះ៕




| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 689 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## HIDE ALL IP លាក់ IP ប្រកបដោយសុវត្ថិភាពបំផុត

HIDE ALL IP ជាកម្មវិធីដែលមានទំហំតូច និងមានមុខងារសម្រាប់លាក់នូវ IP ដែលល្អបំផុតក្នុងចំណោមកម្មវិធីជាច្រើនទៀត។ វាមានលក្ខណៈពិសេសដែលអាចធ្វើការលាក់នូវ IP របស់អ្នកគេចចេញពី Snoopers ឬ Hackers និងអាចធ្វើឲ្យអ្នកអាចលាក់នូវអត្តសញ្ញាណរបស់អ្នកផងដែរ។ លោកអ្នកអាចធ្វើការផ្លាស់ប្តូរនូវ IP ថ្មីនៅលើ IP Private Servers ដើម្បីធ្វើការស្វែងរកនូវអ្វីដែលអ្នកចង់បាន។ នៅពេលនោះ Servers មិនអាចដឹងថា អ្នកផ្តល់នូវ IP ដែលក្លែងក្លាយនោះទេ ដែលកត្តានេះហើយធ្វើឲ្យអ្នកមានសុវត្ថិភាពបំផុត។ មុខងារពិសេសរបស់វាមានដូចជា ការផ្លាស់ប្តូរនូវ IP Address ការផ្លាស់ប្តូរនូវទីតាំង ការ Encrypt នូវរាល់ទិន្នន័យដែលបានបញ្ជូន និងការ Remote DNS Lookups ផងដែរ៕




| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 4 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## IObit Driver Booster PRO ងាយស្រួលបំផុតក្នុងការស្វែងរក Driver

IObit Driver Booster PRO គឺជាកម្មវិធីសម្រាប់ធ្វើការស្វែងរក Driver ដែលមិនបានតម្លើងបានត្រឹមត្រូវ ឬខ្វះខាតនៅលើកុំព្យូទ័ររបស់អ្នក។ នៅពេលខ្លះលោកអ្នកមិនអាចធ្វើការ Update នូវ Driver នៅក្នុងកុំព្យូទ័ររបស់អ្នកបានអស់នោះទេ ដូចនេះអ្នកត្រូវធ្វើការតម្លើងនូវកម្មវិធីនេះដើម្បីជួយសម្រួលការងាររបស់អ្នក។ IObit Driver Booster PRO ផ្តល់នូវមុខងារសម្រាប់ធ្វើការទាញយក និង Update នូវ Drivers បានយ៉ាងស្វ័យប្រវត្តិ និងងាយស្រួលបំផុត។ ដូចនេះ ជាមួយនឹងកម្មវិធីនេះ Drivers របស់កុំព្យូទ័រអ្នកគឺនៅតែ Up-to-date រហូតដែលធ្វើឲ្យដំណើរការល្បឿនរបស់កុំព្យូទ័រកាន់តែលឿនជាងមុន៕




| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 11 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |




# គ្រប់គ្រង Project បានងាយ ជាមួយ Project KickStart Pro 5

សម្រាប់លោកអ្នកដែលជាអ្នកគ្រប់គ្រង Project តែងតែត្រូវការកម្មវិធីមួយចំនួនក្នុងការជួយសម្រួលដល់ការងាររបស់ខ្លួនជាមួយកម្មវិធី Project KickStart Pro 5 បានជួយដល់លោកអ្នកក្នុងការបង្កើតគំនិតថ្មីៗ ដោយមានគម្រោងសំនួរមួយចំនួនផ្តល់នូវការណែនាំដែលត្រូវការ និងអនុញ្ញាតិឲ្យអ្នកបង្កើត Project បានលឿន និងការរៀបចំ Project ការបំពេញដំណាក់កាលគោលដៅការដោះស្រាយឧបសគ្គជាមួយដំណោះស្រាយល្អៗ។ Project KickStart Pro 5 ត្រូវបានប្រើប្រាស់ដើម្បីទទួលនូវគំនិតច្នៃប្រឌិតថ្មីការធ្វើដំណោះស្រាយជាច្រើន និងដើម្បីបង្កើនប្រសិទ្ធភាពការងាររបស់លោកអ្នក ។

## លក្ខណៈពិសេសរបស់កម្មវិធី

- មាន៦ដំណាក់កាល wizard ដែលណែនាំបានច្បាស់ដើម្បីឲ្យអ្នកបង្កើតគម្រោង

- មានសមត្ថភាពខ្លាំង ដំណើរការសំនួរនិងចម្លើយ នឹងផ្តល់ឲ្យលោកអ្នកនូវការយល់ដឹងបានកាន់តែច្រើនទៅលើ project ។

- ឧបសគ្គ ហានិភ័យ និងដំណោះស្រាយនៅខណៈពេលស្របគ្នាវាអាចជួយឲ្យលោកអ្នកដើម្បីបង្កើត និងកំណត់បាននូវគោលដៅច្បាស់លាស់ ហើយថែមទាំងមានសន្ទុះដំណើរការលឿនជាមួយ projects ទៀតផង។ គ្រប់ការធ្វើអាជីវកម្មដាច់ខាតត្រូវតែរៀនពី ថាតើត្រូវដោះស្រាយបញ្ហាបែបណាដើម្បីឲ្យអាជីវកម្មរបស់ខ្លួននៅបានយូរអង្វែង និងទទួលបានជោគជ័យ ។ Project KickStart Pro ជួយដល់លោកអ្នកយល់ពីបញ្ហាបានច្បាស់អាចដោះស្រាយបញ្ហាបានលឿន និងផ្តល់ឲ្យលោកអ្នកជាមួយ streamlined, ការរៀបចំ framework នៅពេលដែលធាតុរបស់ project និង កាលវិភាគត្រូវបានកែប្រែដោយស្វ័យប្រវត្តិដោយផ្តោតទៅលើការងារថ្មី រំលឹកកាលបរិច្ឆេទ ឬ អ្វីផ្សេងដែលបានផ្លាស់ប្តូរ។ ចំណាលពេលតិច ចំណាយថាមពលតិច និងទទួលសក្តានុពលបានពេញលេញ លឿន និងងាយស្រួលបំផុត ។

- ជំនាញតារាង Gantt charts ផ្តល់ឲ្យអ្នកនូវសំណុំនៃភាពអាស្រ័យគ្នារវាងការងារដូចជាការផ្លាស់ប្តូកាលបរិច្ឆេទស្វ័យប្រវត្តិ កែប្រែធាតុរបស់ project ។ បង្កើនកិច្ចសហប្រតិបត្តិការនិងទំនាក់ទំនងជាក្រុម អាចទាញទិន្នន័យចេញពី Ms Project, Outlook, Word និង Excel លោកអ្នកអាចបង្កើតជាស្លាយ (slide) បានភ្លាមៗនៅលើ project អាចយកទិន្នន័យចេញពី MindJet MindManager, WBS Chart, ACT!

## ការដំឡើង

ដើម្បីធ្វើការតម្លើង Project KickStart Pro 5 លោកអ្នកគ្រាន់តែចូលទៅកាន់វែបសាយរបស់ Project KickStart Pro 5 ដើម្បី ដោនឡូតបន្ទាប់មកលោកអ្នកអាចធ្វើតម្លើងវាបានយ៉ាងងាយស្រួល។

ចុចលើ file ឈ្មោះ PKS5Setup.exe ដើម្បី Run រួចជ្រើសរើសយក yes បន្ទាប់មកទៀតចុចលើពាក្យ Next




រង់ចាំការ install




ជ្រើសរើសយក I accept the term of the license agreement បន្ទាប់មកចុច Next




ជ្រើសរើសទីតាំងដែលត្រូវដាក់ និង ចុច Next



ជ្រើសរើសទីតាំងដែលត្រូវរក្សាឯកសារទុក រួចចុច Next




ធ្វើការរង់ចាំ




បញ្ចប់ការតម្លើង




## ស្វែងយល់ពី Tool របស់កម្មវិធី

ពេលដំណើរការកម្មវិធីដំបូងកម្មវិធីនឹងបង្ហាញផ្ទាំងដើម្បីឲ្យលោកអ្នកជ្រើសរើសជាមួយ Project ថ្មី ឬមួយបើកនូវ Project ដែលមានស្រាប់ ។




បើជ្រើសរើសយក Start a new project នឹងចេញផ្ទាំងដូចខាងក្រោមដើម្បីបញ្ចូលឈ្មោះរបស់ project



**Phase** ជាប្រភេទដំណាក់កាលនីមួយៗរបស់ project




**Goals** ប្រភេទគោលដៅរបស់ project




**Similar :** ជ្រើសរើស project ដែលមានលក្ខណៈស្រដៀងគ្នា




**People :** ឈ្មោះរបស់អ្នកចូលរួមក្នុង project




**Obstacles :** បញ្ជីនៃឧបសគ្គដែលកើតមាននៅក្នុង project




**Assign :** ផ្តល់ការងារទៅឲ្យបុគ្គលិកនីមួយៗ




**Tasks :** សម្រាប់ធ្វើការរំលឹក និងកែប្រែបញ្ជីរនៃការងារ




**Schedule :** តារាង Gantt Chart ។



# ជម្រើសទាំង 10 សម្រាប់កុំព្យូទ័រយួរដៃ




Top Ten Computer Top Ten Computer Top Ten Computer Top Ten Computer Top Ten Computer Top Ten Computer Top

## Acer Aspire E1 Series




ទោះបីជា Acer Aspire E1 Series មិនជាប់លំដាប់កំពូលក៏ដោយតែវាក៏មានចំណុចល្អផ្សេងពីគេដែរ កម្រាស់ស្តើងល្មមងាយយកតាមខ្លួន ដែលមានវិមាត្រ 5 x 10 x 1.05 អ៊ីង និងមានទំហំក្រាហ្វិកធំធ្វើឲ្យរូបភាពច្បាស់ល្អ ។ Acer Aspire E1 Series មាន Hard disk ទំហំ 500GB ជាមួយអង្គចងចាំ (RAM) ទំហំ 4GB ចំណែកឯល្បឿនវិញស្ថិតនៅកម្រិតមធ្យមនៅឡើយទេ ។

| អេក្រង់ | 14" 15" 16" |
|---|---|
| CPU | Intel Core i3 |




## Dell Inspiron 5000 Series

លោកអ្នកអាចធ្វើការភ្ជាប់បណ្តាញផ្សេងៗបានយ៉ាងងាយស្រួលជាមួយកុំព្យូទ័រ ។ Dell Inspiron 5000 Series មានរូបរាងដែលគួរឲ្យស្រលាញ់ពេញចិត្ត និងមានទម្ងន់ស្រាល ហើយ Hard disk ទំហំ 1TB តែមានអង្គចងចាំ (RAM) ទំហំរហូតដល់ 16GB ថែមទាំងមានថាមពលថ្មដែលអាចប្រើប្រាស់បានយូរជាមួយ CPU ប្រភេទ Intel Core i3 ។

9

| អេក្រង់ | 14" 15" |
|---|---|
| CPU | Intel Core i5 |




## Toshiba Satellite E Series

មានថាមពលថ្មកាន់បានរហូតដល់ 8 ម៉ោង ទោះបីដំណើរការយូរប៉ុណ្ណាក៏ Toshiba Satellite E Series មិនក្តៅខ្លាំងដែរ ។ Toshiba Satellite E Series ក៏មានកម្រិតភាពច្បាស់មិនចាញ់គេដែរគឺ 1366 x 768 ភិចសែល មានទម្ងន់ត្រឹមតែ 5 ផោនតែប៉ុណ្ណោះ ហើយអាចធ្វើការជ្រើសរើសទំហំអេក្រង់ 14 អ៊ីងឬ 15 អ៊ីង ដែលមានវិមាត្រ 14.9 x 9.8 x 0.85 អ៊ីង ។

8

| អេក្រង់ | 14" 15" 17" |
|---|---|
| CPU | Intel Celeron |




## Acer Aspire E Series

ជាកុំព្យូទ័រមួយដែលមានផត (port) ច្រើន ហើយវាក៏ជាជម្រើសល្អសម្រាប់លោកអ្នកដែលចូលចិត្ត ឬត្រូវការការភ្ជាប់បណ្តាញច្រើន ។ Acer Aspire E Series មានសមត្ថភាពខ្លាំង ហើយថែមទាំងមានទំងន់ស្រាលងាយស្រួលយកតាមខ្លួនទៀតផង ដែលមាន វិមាត្រ 15 x 10.1 x 1.2 អ៊ីង ជាមួយល្បឿន processor 2.16GHz និងមានតម្លៃសមរម្យ ។

7

| អេក្រង់ | 14" 15" |
|---|---|
| CPU | Intel Core i3 |



## Lenovo U Series

ជាប្រភេទកុំព្យូទ័រដែលមានភាពធន់ជាមួយការប្រើប្រាស់សម្រាប់ការដំណើរការកម្មវិធីធំៗ ដែលមានកម្រិតភាពច្បាស់ 1600 x 900 Pixels ធ្វើឲ្យរូបភាពច្បាស់ល្អត្រជាក់ភ្នែក កាន់តែពិសេសជាមួយអេក្រង់ទំហំ 14 អ៊ីង ដែលជាទំហំមួយពេញនិយមក្នុងការប្រើប្រាស់ បន្ថែមដោយរូបរាងដ៏ទាក់ទាញ និងសក្តិសមបំផុតសម្រាប់ការប្រើប្រាស់ឲ្យអាជីវកម្មក៏ដូចជាការសិក្សា ។

6

| អេក្រង់ | 11" 14" 15" |
|---|---|
| CPU | Intel Core i5 |



## Asus VivoBook Series

កាន់តែពិសេសជាមួយសមត្ថភាពដ៏អស្ចារ្យរបស់ Asus VivoBook Series ជាមួយរូបរាងស្រស់ស្អាត និងអាច touch screen បានទៀតផង ប៉ុន្តែវាមានល្បឿនស្ថិតនៅកម្រិតមធ្យម ស្របពេលដែលថាមពលថ្មនៅកម្រិតមធ្យមនៅឡើយ ថែមទាំងមាន Hard disk ទំហំ 320GB ដែលអាចបន្ថែមដល់ 1TB ។ លោកអ្នកអាចធ្វើការជ្រើសរើសនូវទំហំអេក្រង់ដែលមានដូចជា 11អ៊ីង 14អ៊ីង និង15.6អ៊ីង ។

5

| អេក្រង់ | 13" |
|---|---|
| CPU | Intel Core i3 |



## Lenovo ThinkPad X240 Series

ទោះបីជាវាមានល្បឿនយឺតជាងគេបន្តិចក៏ដោយតែក៏បានដល់ 1.7GHz ប៉ុន្តែក៏នៅវាមានសមត្ថភាពផ្សេងដែលខ្លាំងជាងគេដូចជាភាពធន់មិនសូវក្តៅខ្លាំង ជាមួយថាមពលថ្មដែលអាចប្រើប្រាស់បានដល់ទៅ 20 ម៉ោង។ Lenovo ThinkPad X240 Series បានប្រើប្រាស់ CPU ប្រភេទជា Intel Core i3 (4th Gen) អេក្រង់ទំហំ 13 អ៊ីង ដែលមានកម្រិតភាពច្បាស់ 1366 x 768 ភិចសែល ។

4

| អេក្រង់ | 14" 15" 17" |
| --- | --- |
| CPU | AMD A8 |



## HP Envy Series

បើប្រៀបធៀបជាមួយ MacBook Air ឬក៏ Dell Inspiron វិញ HP Envy Series មានល្បឿនលឿនជាងគេមិនគួរឲ្យជឿ ។ HP Envy Series មានអេក្រង់ទំហំ 15 អ៊ីង ដែលមានវិមាត្រ 14.9 x 9.9 x 1.1 អ៊ីង និង Hard disk មានទំហំ 750GB ជាមួយអង្គចងចាំ (RAM) 6GB ដែលអាចបន្ថែមដល់ទំហំ 16GB ចំពោះ CPU វិញជាប្រភេទ AMD A8 (3rd Gen) មានភាពធន់មិនងាយក្ដៅនោះទេ ។

3

| អេក្រង់ | 14" 15" 17" |
| --- | --- |
| CPU | Intel Core i5 |



## Dell Inspiron 7000 Series

លោកអ្នកនឹងទទួលបានសមត្ថភាពពិសេសពីកុំព្យូទ័រមួយនេះ Dell Inspiron 7000 Series ប្រើប្រាស់ CPU ប្រភេទ Intel Core i5 ជាមួយល្បឿនដែលលឿន 1.7GHz មានអង្គចងចាំ (RAM) 6GB និង Hard disk មានទំហំ 500GB និងរូបរាងដ៏ស្រស់ស្អាតដែលមានវិមាត្រ 14.9 x 10 x 0.8 អ៊ីង មានកម្រិតភាពច្បាស់ 1920x1080 Pixels បន្ថែមដោយថាមពលថ្មប្រើប្រាស់បានយូររហូតដល់ 9 ម៉ោង ។

2

| អេក្រង់ | 11" 13" |
| --- | --- |
| CPU | Intel Core i5 |



## Apple MacBook Air

ពេលបច្ចុប្បន្ននេះ MacBook Air បានឈានដល់លំដាប់ទីមួយដែលមានការគាំទ្រជាច្រើន។ ប្រើប្រាស់ CPU ប្រភេទ Intel Core i5 (4th Gen) ដែលមាន ល្បឿនលឿន 1.4GHz ជាមួយ Hard disk ដែលមានទំហំ 128GB ប្រភេទជា SSD ប៉ុន្តែមានអង្គចងចាំទំហំ 4GB ។ វាប្រើប្រព័ន្ធប្រតិបត្តិការ OS X Mavericks ដែល មានទំហំអេក្រង់ 13 អ៊ីង កម្រិតភាពច្បាស់ 1440 x 900 ភិចសែល ៕

1



# វិធីសាស្ត្រធំៗ ១០យ៉ាង ដើម្បីការពារព័ត៌មានអ្នកនៅលើអ៊ីនធឺណិត

មាននូវធនធានជាច្រើននៅលើអ៊ីនធឺណិត មានវិធីសាស្ត្រជាច្រើនក្នុងការភ្ជាប់ជាមួយមិត្តភ័ក្រ្ត និងទំនាក់ទំនងសង្គម ហើយជារៀងរាល់ថ្ងៃគឺមានអ្វីៗថ្មីជាច្រើន ដែលអ្នកត្រូវស្វែងយល់បន្ថែម។ ដោយឡែកឧក្រិដ្ឋជនក៏បានធ្វើការស្វែងរកនូវតម្លៃនៃពិភពអ៊ីនធឺណិត។ ពួកគេធ្វើការកំណត់គោលដៅចំពោះជនទាំងឡាយណាដែលមិនបានការពារខ្លួនត្រឹមត្រូវ។ ខាងក្រោមនេះគឺជាវិធីសាស្ត្រចំនួន ១០យ៉ាងក្នុងការការពារព័ត៌មានរបស់អ្នកពីការគំរាមគំហែងនានា ហើយនឹងចំណុចខ្សោយដែលធ្វើឲ្យអ្នក គ្រួសារអ្នក និងការងាររបស់អ្នកស្ថិតក្នុងគ្រោះថ្នាក់ ។

## កុំព្យូទ័ររបស់អ្នក

**1** ចូរធ្វើបច្ចុប្បន្នភាពប្រព័ន្ធប្រតិបត្តិការរបស់អ្នក (Operating System) រាល់កម្មវិធីទាំងអស់ដែលអ្នកបានបញ្ចូលក្នុងកុំព្យូទ័រ ហើយដែលសំខាន់បំផុតនោះ គឺកម្មវិធីកំចាត់ និងទប់ស្កាត់មេរោគ (antivirus software)។ បើកឲ្យមានមុខងារបច្ចុប្បន្នភាពដោយស្វ័យប្រវត្តិ ហើយអនុញ្ញាតឲ្យកុំព្យូទ័ររបស់អ្នកធ្វើបច្ចុប្បន្នភាពដោយខ្លួនឯង។ ចូរធ្វើការ boot កុំព្យូទ័រឡើងវិញបើសិនជាវាត្រូវការ ។

**2** លុបចោលនូវកម្មវិធីទាំងឡាយណាដែលអ្នកមិនប្រើ។ កម្មវិធីដែលហួសសម័យកាល ជាទូទៅគឺមានបញ្ហាសន្តិសុខជាច្រើន ហើយបើសិនជាអ្នកមិនធ្វើការប្រើប្រាស់វា ហេតុអ្វីមិនធ្វើការលុប (uninstall) វាចោលទៅដើម្បីឲ្យ hard drive របស់អ្នកមានទំហំទំនេរ ហើយក៏ធ្វើឲ្យកុំព្យូទ័ររបស់អ្នកមានសន្តិសុខមួយកម្រិតទៀត។

**3** ចូរដាក់មុខងារ screen-saver ដែលមានពាក្យសម្ងាត់ដើម្បីធ្វើការបើកកុំព្យូទ័ររបស់អ្នក។ ជារឿយៗ (មាននៅក្នុងមជ្ឈដ្ឋានចែករំលែកជាមួយមិត្តរួមបន្ទប់ ឬមិត្តរួមការងារ) ដែលមិត្តភ័ក្ដិរបស់អ្នកអាចធ្វើការផ្ញើរអ៊ីម៉ែលចេញពីកុំព្យូទ័ររបស់ ឬក៏ធ្វើការទាញយកនូវកម្មវិធីមិនសមរម្យផ្សេងៗដោយចៃដន្យ។

**4** បើសិនជាអ្នកមាននូវ Laptop សូមដំណើរការមុខងារបំលែងទិន្នន័យក្នុង hard disk (disk encryption)។ វានឹងអាចធ្វើការការពារទិន្នន័យនៅក្នុង Laptop របស់អ្នក បើសិនជា laptop របស់អ្នកត្រូវបានគេលួច។ ជាមួយគ្នានេះដែរ សូមទិញនូវខ្សែចាក់ (cable lock) ដើម្បីចាក់ laptop របស់អ្នក ទៅនឹងតុ។




## វិបសាយរបស់អ្នក

**5** ចូរមានការប្រុងប្រយ័ត្ននូវអ្វីដែលអ្នកបានបង្ហោះនៅក្នុងបណ្ដាញទំនាក់ទំនងសង្គមនូវព័ត៌មានអំពីខ្លួនអ្នក មិត្តភ័ក្ដិ ក្រុមគ្រួសារ និងមិត្តរួមការងារ និងការងាររបស់អ្នក។ ចូរចងចាំថា នៅលើដែលឡើងនៅលើអ៊ីនធឺណិតហើយគឺវានៅតែនៅលើអ៊ីនធឺណិត ជាពិសេសនោះគឺរូបភាព។ ដែរ ចូរប្រើប្រាស់នូវ user IDs និង passwords ផ្សេងៗគ្នា សម្រាប់វិបសាយផ្សេងៗគ្នាដែរ។ ហេតុដូច្នេះហើយ បើសិនជាជនអាក្រក់ធ្វើការលួចបានពាក្យសម្ងាត់នៅក្នុងវិបសាយមួយ គណនីរបស់អ្នកនៅក្នុងវិបសាយផ្សេងទៀតមិនប៉ះពាល់ឡើយ។

**6** ចូរប្រើប្រាស់ពាក្យសម្ងាត់សម្រាប់វិបសាយដែលមានភាពលំបាក ប៉ុន្តែងាយស្រួលសម្រាប់អ្នកចងចាំ។ បើសិនជាអាច ចូរប្រើប្រាស់នូវ passphrase ជាជាង password ។ ឧក្រិដ្ឋជនដឹងនូវពាក្យសម្ងាត់ដែលពេញនិយមប្រើប្រាស់ ហេតុដូច្នេះហើយអ្នកត្រូវតែជៀសវាងការប្រើប្រាស់ពាក្យសម្ងាត់ដូចជា "123456" ឬ "Password1"។ បន្ថែមជាមួយគ្នានេះ

**7** ចូរធ្វើការផ្ដោតចំណាប់អារម្មណ៍ទៅលើសកម្មភាពរបស់អ្នកនៅលើអ៊ីនធឺណិត។វិបសាយប្រភេទ Phishing ជាច្រើនមើលទៅហាក់ដូចជាស្របច្បាប់ តែបើសិនជាអ្នកមើលទៅក្នុង Address bar ឲ្យបានច្បាស់បន្តិចទៀតនោះ អ្នកនឹងឃើញថាអ្នកមិនមែននៅក្នុងវិបសាយពិតប្រាកដទេ។ ចូរគិតឲ្យបានពីរដងមុនពេលវាយបញ្ចូលព័ត៌មានផ្ទាល់ខ្លួននៅក្នុងវិបសាយ ។




## ព័ត៌មានរបស់អ្នក

**8** ចូរមានការប្រុងប្រយ័ត្នជាមួយនឹងកម្មវិធី peer-to-peer ឬក៏ file-sharing។ កម្មវិធីទាំងនោះមិនគួរបញ្ចូលវានៅក្នុងកុំព្យូទ័រការិយាល័យឡើយ ហើយបើសិនជាអ្នកបញ្ចូលវានៅក្នុងកុំព្យូទ័រនៅផ្ទះ ចូរចាប់អារម្មណ៍ទៅលើឯកសារណាដែលអ្នកបានចែករំលែកនៅក្នុង hard drive របស់អ្នក។

**9** នៅពេលដែលអ្នកចុចទៅលើ "reply to all" នៅក្នុងអ៊ីម៉ែល ចូរត្រួតពិនិត្យលើរាល់អាសយដ្ឋានអ៊ីម៉ែលនិមួយៗ ដើម្បីប្រាកដថា អ្នកដឹងថាអ៊ីម៉ែលរបស់អ្នកនឹងទៅណា។ ជាមួយគ្នានេះផងដែរ ចូរមានការប្រុងប្រយ័ត្នខ្ពស់ បើសិនជាអ្នកធ្វើការឆ្លើយតបចេញពី online group។ ការឆ្លើយតបរបស់អ្នកអាចទៅដល់ក្រុមទាំងមូលមិនមែនបុគ្គលដែលអ្នកចង់ឆ្លើយឡើយ។

**10** ពេលមានបញ្ហាផ្សេងៗ ត្រូវដឹងថាតើត្រូវទូរស័ព្ទទៅអ្នកណាដែលអាចជួយអ្នកបាន។ បន្ថែមជាងនេះទៅទៀត ចូរធ្វើការចម្លងទុកនូវរាល់ព័ត៌មាន (passwords, credit card numbers, bank account information, etc.) ដោយសរសេរវាទុកក្នុងក្រដាស ហើយចាក់សោរវាទុកនៅក្នុងទូរបស់អ្នក ។



# ស្វែងយល់ពីគន្លឹះប្រើប្រាស់កុំព្យូទ័រ Quick Study

- កំណត់ពេលវេលាបិទកុំព្យូទ័ររបស់អ្នកដោយស្វ័យប្រវត្តិ
- របៀបប្រើប្រាស់ Desktop បានច្រើនក្នុងពេលតែមួយនៅក្នុង Windows 10
- របៀបចាក់តន្ត្រីរបស់ YouTube នៅក្នុងកម្មវិធីចាក់របស់ iOS 7



# កំណត់ពេលវេលាបិទកុំព្យូទ័ររបស់អ្នកដោយស្វ័យប្រវត្តិ

តើអ្នកតែងតែភ្លេចបិទកុំព្យូទ័ររបស់អ្នកទេមុនពេលដែលអ្នកចូលគេង មែន ឬទេ? ខាងក្រោមនេះជាវិធីសាស្ត្រដែលជួយដោះស្រាយបញ្ហាខាងលើ ៖




បើក Task Scheduler: លោកអ្នកគ្រាន់តែចុចលើ Start បន្ទាប់មកបើក Control Panel ជ្រើសរើស យក System and Security បន្ទាប់មកទៀត select យក Administrative Tools។ ជាចុងក្រោយចូរជ្រើសរើសយកពាក្យ Task Scheduler ។ តែបើអ្នកប្រើប្រាស់ Windows 8 វិញចូរចុចលើ  Win key បន្ទាប់មកសរសេរពាក្យ Schedule tasks ។



ចុចលើពាក្យ Create Basic Task: ជម្រើសមួយនេះស្ថិតនៅក្នុងជម្រើស Actions menu ហើយមានទីតាំងស្ថិតនៅខាងស្តាំនៃផ្ទាំង window ។ អ្នកនឹងទាមទារឲ្យដាក់ឈ្មោះការងារនេះ និងការពិពណ៌នាអំពីការងារនោះ។ បន្ទាប់មកទៀតចុចលើពាក្យ Next ។




ជ្រើសរើស Choose the frequency: នៅក្នុងខណៈនេះ យកពាក្យ Daily នៅក្នុងជម្រើស Task Trigger បន្ទាប់មកចុចលើប៊ូតុង Next ។ ជ្រើសរើសពេលវេលាណាមួយដែលអ្នកចង់បិទកុំព្យូទ័ររបស់អ្នកទៅតាមកាលវិភាគដែលអ្នកចង់បាន។ ជាចុងក្រោយចុចពាក្យ Next ។




ជ្រើសរើស Start a program: ជម្រើសមួយនេះស្ថិតក្នុង Action menu ជាទូទៅវាត្រូវបានជ្រើសរើស ដោយស្វ័យប្រវត្តិ។ សម្រាប់ជំហានបន្ទាប់ ចុចលើប៊ូតុង Next ។




បញ្ចូលទីតាំងសម្រាប់ធ្វើការបិទម៉ាស៊ីនកុំព្យូទ័រ : ជាទូទៅនៅពេលដែល window ដំណើរការក្នុងការបិទនោះគឺវាចាប់ផ្តើមដំណើរកម្មវិធី shutdown ។ ដូចនេះនៅក្នុងប្រអប់ Program/script ចូរវាយ C:\Windows\System32\shutdown.exe ជាការស្រេច។ បន្ទាប់មកសូមចុច Next ។




ត្រួតពិនិត្យការកំណត់របស់អ្នក : នៅក្នុងដំណាក់កាលនេះ វាបង្ហាញពីអ្វីដែលអ្នកបានជ្រើសរើសរួចមក តែឲ្យប្រាកដថាអ្នកជ្រើសរើសថ្ងៃត្រឹមត្រូវតាមដែលអ្នកចង់បាន។ បើគ្មានបញ្ហាអ្វីនោះទេ ចុចលើប៊ូតុង Finish ដើម្បីធ្វើការ save កិច្ចការរបស់អ្នក។ នោះអ្នកនឹងអាចបិទកុំព្យូទ័ររបស់អ្នកជារៀងរាល់ថ្ងៃទៅតាមម៉ោងដែលអ្នកបានកំណត់ ៕



# របៀបប្រើប្រាស់ Desktop បានច្រើនក្នុងពេលតែមួយ នៅក្នុង Windows 10




នេះគឺជាលើកដំបូងហើយដែល Windows 10 ផ្តល់នូវលក្ខណៈពិសេសមួយដែល អនុញ្ញាតិឲ្យអ្នកប្រើប្រាស់អាចអាចធ្វើការបង្ហាញផ្ទៃ desktops បានច្រើននៅក្នុងពេលតែមួយ។

នៅក្នុងការដាក់បង្ហាញ Windows 10 អ្នកអាចធ្វើការបន្ថែមផ្ទៃនៃ desktops ទៅតាមអ្វីដែលអ្នកចង់បានដោយមានភាពងាយស្រួល និងរហ័សផងដែរ។ តែយ៉ាងណានៅមានលក្ខណៈផ្សេងទៀតដែលមិនទាន់បានផ្តល់ភាពងាយស្រួលប្រើប្រាស់នៅឡើយទេ។

## Step 1: ការបន្ថែម desktop មួយ

ដើម្បីធ្វើការបន្ថែម desktops ចូរបើក Task View pane ថ្មីមួយ ដោយចុចលើប៊ូតុង Task View ( ប្រអប់រាងចតុកោណកែង 2 គនៅលើគ្នា ) ដែលស្ថិតនៅលើ taskbar ឬអ្នកគ្រាន់តែចុច Windows Key + Tab ជាការស្រេច។ នៅក្នុង Task View pane ចូរចុចលើពាក្យ Add a desktop ដើម្បីធ្វើការបន្ថែម desktop ថ្មី។ ទន្ទឹមនឹងនេះ លោកអ្នកក៏អាចប្រើប្រាស់ shortcut keyboard ដើម្បីធ្វើរឿងនេះ ដោយគ្រាន់តែចុច Windows Key + Ctrl + D ប៉ុណ្ណោះ ។



## Step 2 : ការប្តូរពី desktop មួយទៅកាន់ desktop មួយទៀត

ដើម្បីធ្វើការផ្លាស់ប្តូរពី desktop មួយទៅកាន់ desktop មួយទៀតនោះ អ្នកចាំបាច់បើក Task View pane ហើយចុចលើ desktop ណាមួយដែលអ្នកចង់បង្ហាញ ឬក៏ប្រើប្រាស់វិធីដែលលឿន និងមានភាពងាយស្រួលដោយលោកអ្នកគ្រាន់តែចុច shortcut keyboard គឺ Windows Key + Ctrl + Left Arrow ឬ Windows Key + Ctrl + Right Arrow ប៉ុណ្ណោះ។




## Step 3 : ការប្តូរទីតាំងនៃ window ពី desktop មួយទៅកាន់ desktop មួយទៀត

ដើម្បីធ្វើការផ្លាស់ប្តូរទីតាំងផ្ទាំង window នៅក្នុង desktop មួយទៅកាន់ desktop មួយទៀត នោះ ដំបូងអ្នកត្រូវតែបើក Task View pane បន្ទាប់មកអូស mouse ដាក់ពីលើ desktop ណាមួយ ដែលមានផ្ទាំង windows ដែលអ្នកចង់ធ្វើការផ្លាស់ទី។ ភ្លាមនោះចុច mouse ស្តាំលើ window នោះ បន្ទាប់ជ្រើសរើសយកពាក្យ Move to ហើយធ្វើការជ្រើសរើសផ្ទាំង desktop ណាមួយ ដែលអ្នកចង់បាន។




## Step 4: ការបិទផ្ទាំង desktop

ដើម្បីធ្វើការបិទនូវរាល់ផ្ទាំង desktop ទាមទារឲ្យអ្នកបើកនូវ Task View pane រួចអូស mouse ពីលើផ្ទាំង desktop ណាដែលអ្នកចង់បិទបន្ទាប់មកចុច X ដែលលេចឡើងនៅជ្រុងខាងស្តាំផ្នែកខាងលើនៃផ្ទាំងdesktop ដើម្បីបិទវា។ ដូចគ្នានេះដែរលោកអ្នកក៏អាចបិទ desktop ណាមួយដោយប្រើប្រាស់ shortcut keyboard គឺ Windows Key + Ctrl + F4 នោះវានឹងដំណើរការបិទ desktop ដែលអ្នកកំពុងស្ថិតនៅ ៕



# របៀបចាក់តន្ត្រីរបស់ YouTube នៅក្នុងកម្មវិធីចាក់តន្ត្រីរបស់ iOS 7

អ្នករាល់គ្នាអាចនឹងចងចាំពេលដែល YouTube បានដាក់កម្មវិធីនៅលើឧបករណ៍ iOS ដូចនេះអ្នកអាចចាក់វីដេអូជា background របស់ទូរស័ព្ទ iPhone បានផងដែរ។

ប្រព័ន្ធប្រតិបត្តិការ iOS 6 គឺមិនមានលក្ខណៈពិសេសនេះនោះទេ តែចំពោះ iOS 7 មានបំពាក់នូវលក្ខណៈដ៏ពិសេសនេះ។ វាជាចំណេះដឹងមួយដែលនឹងត្រូវយកមកបង្ហាញលោកអ្នកសម្រាប់ពេលនេះ។






## ចាក់វីដេអូនៅក្នុង YouTube ក្នុង Background លើ iOS 7

ជំនួសដោយការប្រើប្រាស់កម្មវិធី YouTube បើកកម្មវិធី Safari និងធ្វើការតភ្ជាប់ទៅកាន់វិដេអូឃ្លីបរបស់ YouTube ហើយចុចដើម្បីស្តាប់កម្សាន្ត។




ក្នុងករណីដែលលោកអ្នកចង់ប្រើប្រាស់កម្មវិធីផ្សេងៗខណៈពេលដែលលោកអ្នកកំពុងចាក់វីដេអូរបស់ YouTube នៅក្នុង background របស់ទូរស័ព្ទ iPhone ដែលមាន iOS 7 នោះ លោក អ្នកគ្រាន់តែចុចលើប៊ូតុង Home ជាការស្រេច។

ពេលដែលអ្នកកំពុងស្ថិតនៅលើអេក្រង់របស់អ្នកនោះ អ្នកអាចអូសនៅលើអេក្រង់របស់អ្នកពីក្រោមឡើងលើ រួចជ្រើសរើសយកពាក្យប៊ូតុង Play/Pause នោះលោកអ្នកនឹងអាចស្តាប់តន្ត្រី របស់ YouTube ដែលអ្នកបានជ្រើសរើសនោះ និងប្រើប្រាស់កម្មវិធីផ្សេងៗទៀតក្នុងពេលដំណាលគ្នាបាន។ ទោះបីជាអ្នកចាក់សោ ផ្ទៃអេក្រង់របស់អ្នកក៏អ្នកនៅតែមានលទ្ធភាពក្នុងការស្តាប់តន្ត្រីនេះផងដែរ៕








# Far Cry 4

## ដំណើរផ្សងព្រេង រំដោះសន្តិភាពរបស់ Ghale

Far Cry 4 ជាហ្គេមជំនាន់ទី 4 របស់ Far Cry ដែលត្រូវបានចែកចាយយ៉ាងជោគជ័យនៅអាមេរិចខាងជើង អូស្ត្រាលី និងអឺរ៉ុបនៅក្នុងថ្ងៃទី 18 ខែវិច្ឆិកា ឆ្នាំ 2014 ហើយវាត្រូវបានដាក់លក់នៅក្នុងទីផ្សាររបស់ជប៉ុននៅក្នុងថ្ងៃទី 22 ខែមករា ឆ្នាំ 2015 នេះ។

តួអង្គសំខាន់នៅក្នុងហ្គេមនេះមានឈ្មោះថា Ajay Ghale ដែលចាកចេញពីតំបន់ Nepali នឹងវិលត្រលប់ទៅកាន់ទឹកដីកំណើត Kyrati-American ដើម្បីធ្វើឲ្យប្រទេសមានសន្តិភាពវិញ។ Ajay ត្រូវធ្វើសង្គ្រាមនៅក្នុងស្រុកជាមួយការដឹកនាំទ័ពរបស់ Kyrat Royal Army ប្រយុទ្ធជាមួយនឹងស្តេច Pagan Min និង Golden Path ដែលជាសង្គ្រាមរើបំរះដើម្បីគេចចេញពីការគ្រប់គ្រងរបស់ស្តេច Kyrat និង Min នេះ។

ដូចនេះ តើអ្នកអាចជួយ Ghale ធ្វើឲ្យប្រទេសទឹកដីកំណើតរបស់អ្នកមានសន្តិភាពឡើងវិញនោះទេ? សូមឲ្យដំណើរផ្សងព្រេងរបស់អ្នកជួយ Ajay Ghale ទទួលបានយ៉ាងជោគជ័យនិងស្វែងរកសន្តិភាពយ៉ាងនឹងនរសម្រាប់ប្រទេសរបស់អ្នក៕

Developer: Ubisoft Montreal

Publisher: Ubisoft

Platform: Microsoft Windows/ PlayStation 3/ PlayStation 4/ Xbox 360/ Xbox One

ថ្ងៃចេញផ្សាយ: 22 ខែមករា ឆ្នាំ 2015

ប្រភេទហ្គេម: ផ្សងព្រេង/ ការបាញ់ប្រហារ

# Fantasy Life
# ខ្សែជីវិតពោរពេញដោយក្តីរីករាយ

Fantasy Life ជាប្រភេទវីដេអូហ្គេម Role Playing ដែល Develop ដោយក្រុម Level-5 និងមានជំនួយការ Brownie Brown ដែលត្រូវបានធ្វើឡើងសម្រាប់ក្រុមហ៊ុន Nintendo DS។ គ្រាន់តែចាប់ផ្តើមចេញលក់ភ្លាម វាបានលក់ដាចអស់ដល់ទៅ 300,000 កូពីនៅក្នុងប្រទេសជប៉ុនដែលនិយាយពីភាពអស្ចារ្យរបស់ពិភព Reveria ដែលមានក្រុងស្រស់ស្អាតជាច្រើនដូចជាទេសភាពព្រៃព្រឹក្សា និងមានភ្នំទៀតផង។

គ្រប់តួអង្គទាំងអស់គឺជ្រើសរើសដោយស្តេច King Erik ដែលពួកគេសុទ្ធតែជាមនុស្សមានសមត្ថភាពនៅក្នុងទឹកដី Castele (ផ្នែកមួយរបស់ក្រុង Reveria) ដើម្បីធ្វើការសើបអង្កេតទៅលើបញ្ហាមួយចំនួនដែលកើតឡើងនៅក្នុងទឹកដីដ៏សម្បូរសប្បាយមួយនេះ។ អ្នកនឹងជួបផងដែរជាមួយនឹងទេពធីតាមេអំបៅដែលមានឈ្មោះថា Yuelia ដែលអាចនិយាយបាន ហើយត្រូវបានប្រជាជនរបស់ស្តេចនៅក្នុងទីក្រុង Reveria គោរពបូជាផងដែរ៕

Developer: Level-5/ Brownie Brown
Publisher: Level-5/ Nintendo
Platform: Windows
ប្រភេទ៖ Role-Playing
ថ្ងៃចេញផ្សាយ៖ 24 តុលា 2014





# Theatrhythm Final Fantasy: Curtain Call

## រាំងននសង្គ្រាមនៃក្តីស្រម៉ៃដ៏អស្ចារ្យ

Theatrhythm Final Fantasy: Curtain Call គឺជាប្រភេទវីដេអូហ្គេមបែបស្រមើរស្រម៉ៃ ដែលត្រូវបានទទួលការគាំទ្រយ៉ាងខ្លាំងនៅក្នុងប្រទេសជប៉ុននៅថ្ងៃទី 16 ខែកញ្ញា ឆ្នាំ 2014 និងទទួលបានការពេញនិយមនៅទ្វីបអឺរ៉ុបនៅថ្ងៃទី 19 ខែកញ្ញា ឆ្នាំ 2014 ។ អ្នកលេងអាចធ្វើការប្រើប្រាស់នូវតួអង្គជាច្រើនដែលជ្រើសរើសចេញពី Final Fantasy ដែលជាសាច់រឿងប្រភេទចម្រៀងដែលអ្នកលេងត្រូវតែចុងប៊ូតុងបញ្ជាឲ្យបានត្រឹមត្រូវ។

ហ្គេមនេះត្រូវបានបំបែកជាវគ្គធំៗប្លែកៗពីគ្នាជាច្រើនដូចជា Field Stages ដែលជាវគ្គដែលអ្នកលេងត្រូវការគ្រប់គ្រងតួអង្គបានតែមួយគត់។ វគ្គ Battle Songs ជាពេលដែលតួអង្គគ្រប់រូបធ្វើការប្រកួតជាមួយនឹងបិសាចនានា និងវគ្គ Event Stages ជាវគ្គដែលអ្នកត្រូវលេងប្រកួតជាមួយនឹង Background របស់បទចម្រៀងដែលជាគំនូរស្រម៉ៃនោះ។ ចំណែក Versus Mode គឺជាវគ្គដែលមនុស្សពីរនាក់ត្រូវធ្វើការប្រកួតជាមួយនឹងដៃគូដែលជាចម្រៀងកំណាព្យនេះផងដែរ។

Curtain Call បានរួមបញ្ចូលបទចម្រៀងដល់ទៅ 221 បទដែលសុទ្ធតែបទចម្រៀងដែលដកស្រង់ចេញពី Final Fantasy XIV: A Realm Reborn, Final Fantasy X-2, Final Fantasy XIII, Lightning Returns, Final Fantasy Type-0 ជាពិសេសរឿង Final Fantasy VII: Advent Children, Final Fantasy Adventure, Crystal Chronicles និង Dissidia ផងដែរ ហើយវាថែមទាំងមានតួអង្គដល់ទៅ 60 រូប ៕

Developer: Square Enix 1st
Publisher: Square Enix
Platform: Nintendo 3DS/Windows
ថ្ងៃចេញផ្សាយ: 19 កញ្ញា 2014
ប្រភេទហ្គេម: ចម្រៀងកំណាព្យ



# Fenix Rage

## មួយវិនាទីរត់គេចពីសេចក្ដីស្លាប់

Fenix Rage គឺជាវីដេអូហ្គេមដែលត្រូវបាន Develop ដោយក្រុម Green Lava Studios ដែលមានលក្ខណៈស្រដៀងទៅនឹងហ្គេម Super Meat Boy និង Flappy Bird ផងដែរ។ ហ្គេមនេះត្រូវបានការជម្រុញដោយ Sonic the Hedgehog ដែលមានតួអង្គច្រើនជាង 90 នាក់នោះ។ ហ្គេមនេះត្រូវបានប្រកាសជាផ្លូវការនៅថ្ងៃទី 24 កញ្ញា 2014 ដែលអាចលេងបាននៅលើ Microsoft Windows ហើយនៅដើមឆ្នាំ 2015 នេះវាអាចដំណើរការនៅលើ OS X, PlayStation 4, PlayStation Vita និង Xbox One ផងដែរ។

Fenix ជាតួអង្គវីរបុរសដែលត្រូវធ្វើការកំទេចនូវសត្រូវបិសាចដែលចូលមកបំផ្លាញទីក្រុងរបស់គាត់នោះ។ Fenix អាចលោតបាន និងប្រើប្រាស់ថាមពលពិសេសរបស់គាត់ផងដែរ។ វាមានវគ្គច្រើនជាង 200 វគ្គហើយអ្នកលេងត្រូវធ្វើយ៉ាងណាលោតទៅកាន់ទ្វារដែលមានពណ៌ខៀវនោះ ដើម្បីទៅកាន់វគ្គបន្ទាប់ទៀត។

គួរបញ្ជាក់ផងដែរថា ហ្គេមនេះត្រូវបានមនុស្សនៅលើពិភពលោកធ្វើការប្រៀបធៀបជាមួយនឹងហ្គេម Super Meat Boy និង Flappy Bird ដែលជាហ្គេមពិបាកលេងបំផុតនៅក្នុងលោកព្រោះវាងាយស្លាប់ និងពិតជាសប្បាយរីករាយណាស់ដែលអ្នកពិតជាចង់ឆ្លងទៅកាន់វគ្គបន្ទាប់ទៀតដោយអន្ទះសារបំផុត៕

Developer: Green Lava Studios

Publisher: Reverb Triple XP

Platform: Microsoft Windows/ OS X/ PlayStation 4/ PlayStation Vita/ Xbox One

ថ្ងៃចេញផ្សាយៈ 24 កញ្ញា 2014

ប្រភេទៈ រត់គេច



# ការរចនា ស៊ុមដ៏ស្រស់ស្អាត ជាមួយ Illustrator

នៅក្នុងការបង្រៀននេះលោកអ្នកនឹងប្រើ Blob Brush Tool នៅក្នុងកម្មវិធី Adobe Illustrator ដើម្បីបង្កើតផ្នែកតូចៗនៃការរចនាម៉ូដដោយ copied, pasted, និង rotated ដើម្បីបង្កើតស៊ុមសម្រាប់តុបតែងពេញលេញមួយ។ ដោយមានការរួមបញ្ចូលគ្នារវាងការភ្ជាប់ធាតុនីមួយៗជាមួយនឹងរូបឆ្នូត រាងជាមូលដ្ឋាន ផ្កា និងធាតុផ្សំជាច្រើនទៀត លោកអ្នកនឹងមាន vector pieces ត្រៀមរួចជាស្រេចសម្រាប់ជាតម្រូវការការរចនារូបភាពដ៏ឆើតឆាយ ។



# 1. បង្កើតសមាសធាតុស៊ុម

## ជំហានទី 1

ប្រើប្រាស់ Blob Brush Tool (Shift-B) ចុច Enter ដើម្បីដំណើរការ options របស់ tool ។ កំណត់ទំហំនៃ brush ទៅ 3 pt ឬក៏ត្រូវតែប្រាកដថា Pressure បានបើក ។ កំណត់ Fidelity ដើម្បីឲ្យសញ្ញាធីកទីបួនបែរទៅខាងស្តាំ (ស្មើរតែរាបស្មើប៉ុន្តែមិនរួមចូលគ្នាទេ) ។

ជាចុងក្រោយត្រូវតែប្រាកដថា Keep Selected មិនត្រូវបានឆែក និង Merge Only with Selection ត្រូវបានឆែក ។ តាមវិធីសាស្ត្រនេះគ្រប់យ៉ាងអ្នកអាចគូសនិងងាយស្រួលកែប្រែ (លុះត្រាតែអ្នកចង់បានអ្វីគ្រប់យ៉ាងដើម្បីបញ្ចូលរួមគ្នាពីការទទួលបានចូលទៅ) ។



## ជំហានទី 2

ឥឡូវយើងមាន tool របស់យើងរួចជាស្រេច ចាប់ផ្តើមការរចនាស៊ុម។ អ្នកអាចចាប់ផ្តើមជាមួយរូបដែលនៅកណ្តាល និងរូបឆ្នូត ឬរូបក្បូចនៅលើទីតាំងណាមួយ។ នៅក្នុងករណីនេះដែរ អាចគូសរូបបេះដូង រូបបេះដូងតូចៗដែលនៅខាងក្នុងវា និងគំនូសឆ្នូតនៅខាងឆ្វេង។ រូបពេជ្រ រាងពងក្រពើ និងរាងផ្កាឲ្យរួចរាល់នៅក្នុងជំហាននេះក៏ល្អដែរ ។



## ជំហានទី 3

ចុច key Alt ឲ្យជាប់ហើយប្រើ Selection Tool (V) ដើម្បីនាំយកគំនូសឆ្នូតទៅខាងស្តាំ។ អ្នកកនឹងឃើញថាអ្នកបានចម្លងវាបានភ្លាមមួយរំពេចនូវរូបរាងមួយនេះយ៉ាងពិសេស។ Right-click ហើយជ្រើសយក Transform > Reflect ដើម្បីត្រលប់រាងរបស់បន្ទាត់ឲ្យនៅលើ Vertical Axis។ ដាក់ច្បាប់ចម្លងត្រឡប់នៅលើផ្នែកខាងស្តាំនៃបេះដូង ( មើលរូបខាងក្រោម )។





## ជំហានទី 4

សូមពិនិត្យទៅលើរូបរាងដែលអ្នកកំពុងបង្កើតធ្វើយ៉ាងណាឲ្យក្លាយជាជ្រុងនៃពហុកោណមួយ។ ស្នាមគួចនិងគំនូសឆ្នូតគួរតែដាក់វាឲ្យចូលទៅក្នុងផ្នែកកណ្តាលនៃការរចនាម៉ូតរបស់អ្នកក៏ដូចជាការធ្វើជាអ្វីដែលអាចតភ្ជាប់ទៅ "ជ្រុង" បន្ទាប់ពីបញ្ចប់រូបរាងមួយ។ យើងបានរកឃើញថារាងដូចផ្កា ឬមានមកុដដូចជាមានតិចតួចនៅក្នុងការងារកំពូលផងដែររួមជាមួយធ្នូតកួចភ្ជាប់បេះដូងកណ្តាល។



## ជំហានទី 5

បន្ទាប់មកត្រូវពង្រីករូបមួយចំនួនដែលទាបជាងឲ្យនៅផ្នែកកណ្តាល។ ជ្រើសរើសរាងអក្សរ V និងបន្ថែមខ្នួចដែលមានទំហំតូចនៅលើជ្រុងណាមួយ។ ប្រសិនបើអ្នករចនាស៊ីមេទ្រីហើយ Copy, Paste និង Reflect អ្វីដែលបានរចនា។ ដាក់ជា Group (Control-G) នូវធាតុដែលបានរចនាទាំងអស់ និងចាប់ផ្តើមបង្កើតផ្នែកនៅសល់របស់ស៊ុម ។



## 2. បង្វិលធាតុដែលបានរចនា

### ជំហានទី 1

Copy និង Paste ក្រុមដែលបានរចនា។ ប្រើប្រាស់ Rotate Tool (R) ដើម្បីបង្វិលក្រុមដែលបាន copied ទៅមុំ 45° ។








## ជំហានទី 2

Copy, Paste, និង Rotate ធាតុដែលបានរចនានិងរៀបចំវាឲ្យនៅជារាងរង្វង់ ឬអដ្ឋកោណ។ ប្រើប្រាស់បន្ទះតម្រឹមដើម្បីធ្វើឱ្យប្រាកដថារាងកណ្តាលកំពូល និងបាត តម្រឹមបញ្ឈរឲ្យនៅកណ្តាល ។

## ជំហានទី 3

ទំហំ គម្លាត និងរូបរាងទាំងអស់ដែលបានរចនារបស់អ្នកអាស្រ័យទៅលើការដាក់ទីតាំងក៏ដូចជាធាតុដែលអ្នកបានបង្កើត។ ក្នុងករណីនេះការរចនាមានរយៈពេលយូរ រាងផ្តេកជាមួយនឹងការបង្កើតចំណុចនៅកណ្តាលនៃទីតាំងនីមួយៗ ។ ដោយសារតែបានបង្វិល 45 ដឺក្រេ នៃធាតុនីមួយៗ មានទីតាំងរូបភាពចំនួនប្រាំបី ។ Group សមាសភាគនីមួយៗរបស់អ្នកជាមួយគ្នានៅពេលដែលបានបញ្ចប់ជាមួយទីតាំង ។ ស៊ុមស្រស់ស្អាតជាលើកដំបូងរបស់អ្នកត្រូវបានបញ្ចប់ ។





## 3. ស៊ុមស្លាយឆ្លាស់

### ជំហានទី 1

ការរចនាបង្វិលឆ្លាស់គ្នានៃធាតុនីមួយៗដោយមុំ 90 ដឺក្រេ ដូច្នេះមានតែបួនជ្រុងនៃការរចនានេះប៉ុណ្ណោះ។ ងាយស្រួលបំផុតដើម្បី Copy, Paste នឹង Rotate ទៅជាមុំ -90 ដឺក្រេ ។



## ជំហានទី 2

បន្ទាប់មក Copied និង Pasted សមាសភាគទាំងពីរ និងបង្វិលក្រុម 180 ដឺក្រេ ដូច្នេះពួកគេហាក់ដូចជាបានតម្រឹមយ៉ាងឥតខ្ចោះ។ ខណៈពេលនេះជាធម្មតាអាចបង្កើត ការរចនាស៊ុមរាងជាការ៉េ ឬរាងដូចប្រអប់ ប្រសិនបើអ្នកបន្ថែមធាតុនៅក្នុងក្រុមថ្មីរវាងការរចនាស៊ុមដំបូង អ្នកអាចប្រមូលចេញ "ជ្រុង" នៃស៊ុម។ លើសពីនេះទៀតអ្នកអាចបន្ថែមធាតុទៅកណ្តាលឬចំហៀងនិងការរក្សាស្រទាប់សមាសភាគស៊ុមដើម្បីបង្កើនភាពស្មុគស្មាញ (រញ៉េរញ៉ៃ) ។






## បញ្ចប់

ខាងក្រោមជាស៊ុមមួយចំនួនដែលបានគូរចរាល់ដោយប្រើវិធីដូចខាងលើ។ បន្ទាប់ពីបានធ្វើការបង្ហាញរួចរាល់ យើងសង្ឃឹមថាលោកអ្នកអាចបង្កើតនូវស៊ុមដ៏ស្រស់ស្អាតបានយ៉ាងងាយស្រួលទៅតាមចំណង់ចំណូលចិត្ត ៕



ចំណាំៈ របៀបមួយចំនួននៃបំណែកខាងក្រោមមានបួនជ្រុង ប្រាំមួយជ្រុង ប្រាំបីជ្រុងរៀងគ្នា និងមានចាប់ពីសាមញ្ញទៅស្មុគស្មាញក្នុងចំនួនសរុបនៃធាតុដែលបានបន្ថែមទៅលើការរចនាស៊ុម ៕




# សំនួរ និង ចម្លើយ

**QUESTION & ANSWER**

ប្រសិនបើមានបញ្ហាសូមទូរស័ព្ទមកកាន់លេខ

**012 999 140**

we live with technology

**ឈ្មោះ: សេង សុផល**

Email: sophalseng@yahoo.com

**សំនួរ ៖** សួស្តីបង ខ្ញុំឈ្មោះ **សេង សុផល** ខ្ញុំក៏ជាប្រិយមិត្តអ្នកអានដែលចូលចិត្តតាមដានជាមួយនឹងទស្សនាវដ្តីទីក្រុងព័ត៌មានវិទ្យា និងទីក្រុងទូរស័ព្ទដែលពេលនេះខ្ញុំអាចមើលវាបានយ៉ាងងាយស្រួលនៅលើទូរស័ព្ទ iPhone របស់ខ្ញុំ។ វាផ្តល់ភាពងាយស្រួល ហើយការចែករំលែករបស់ក្រុមហ៊ុនទស្សនាវដ្តីទីក្រុងព័ត៌មានវិទ្យា និងទីក្រុងទូរស័ព្ទពិតជាមានតម្លៃខ្លាំងណាស់សម្រាប់ខ្ញុំ និងប្រិយមិត្តជាច្រើនទៀត។ សំនួររបស់ខ្ញុំគឺតើធ្វើដូចម្តេចដើម្បីធ្វើការបន្ថែមនូវ Programs, Files និង Folders ទៅកាន់ System Startup នៅក្នុង Windows 8.1? សូមបងជួយបង្ហាញដល់ប្អូនដោយអនុគ្រោះ និងសូមអរគុណចំពោះការចែករំលែកនេះ។

**ចម្លើយ ៖** ជាដំបូង ក្នុងនាមបងជាក្រុមការងាររបស់ទស្សនាវដ្តីទីក្រុងព័ត៌មានវិទ្យា និងទីក្រុងទូរស័ព្ទសូមធ្វើការអរគុណដែលប្អូននៅតែបន្តគាំទ្រទស្សនាវដ្តីរបស់យើង និងបន្តប្រើប្រាស់កម្មវិធីទស្សនាវដ្តីរបស់យើងនៅលើ iOS របស់ប្អូន។ អរគុណសម្រាប់សំនួរនេះ ព្រោះវាជាសំនួរដ៏ល្អ ហើយបងនឹងធ្វើការបកស្រាយពីវិធីសាស្ត្រក្នុងការបន្ថែមនូវ Programs, Files និង Folders ទៅកាន់ System Startup នៅក្នុង Windows 8.1 ដល់ប្អូនដូចខាងក្រោមនេះ៖

ជាទូទៅ កម្មវិធីជាច្រើននៅលើ Windows តែងតែធ្វើការបន្ថែមដោយស្វ័យប្រវត្តិនៅក្នុង System Startup នៅពេលដែលអ្នកតម្លើងវានោះ ។ ជាធម្មតាដើម្បីធ្វើការបន្ថែមកម្មវិធីក្នុង "Startup" Folder អ្នកត្រូវប្រើប្រាស់ Shortcut ចេញពី Desktop នោះ។

ដើម្បីធ្វើការ Copy នូវ Shortcut នៅលើ Desktop នោះសូមធ្វើការ Click ស្តាំនៅលើ Shortcut បន្ទាប់មកចុចពាក្យ "Copy" ។




បើក "Run" Dialog Box ដោយចុច Windows Key + R ។ វាយពាក្យថា "shell:startup" នៅក្នុង "Open" Edit Box បន្ទាប់មកចុច OK ។




បន្ទាប់មកធ្វើការ Right-Click និងជ្រើសរើសពាក្យ "Paste" ។




ពេលនេះ Shortcut នេះនឹងដាក់បញ្ចូលទៅក្នុង Startup Directory ជាក់ជាមិនខាន។



ម៉្យាងវិញទៀត ប្រសិនបើ Shortcut ដែលអ្នកចង់ដាក់ចូលទៅក្នុង Startup Directory នោះមិនស្ថិតនៅលើ Desktop នោះទេ អ្នកអាចបង្កើត Shortcut ចេញពី Program Directory បានតែម្តង។ ដើម្បីធ្វើការបង្កើតនូវ Shortcut នោះអ្នកត្រូវចូលទៅកាន់ Startup Directory បន្ទាប់មក Right-click និងរើសពាក្យ “New” និងជ្រើសរើស “Shortcut” ។




បន្ទាប់មក Create Shortcut Dialogue Box និងបង្ហាញ សូមចុច “Browse” ។




បន្ទាប់មកទៀត “Browse for Files or Folders” Dialog Box បានបង្ហាញ សូមធ្វើការជ្រើសរើសនូវកម្មវិធីណាដែលអ្នកចង់ដាក់ចូលទៅក្នុង Startup ដោយជ្រើសរើសជាប្រភេទ “.exe” File រួចចុច “OK” ។




បន្ទាប់មកចុច Next ។




អ្នកអាចធ្វើការវាយបញ្ចូលនូវឈ្មោះកម្មវិធីនៅត្រង់នេះ បន្ទាប់មកចុច Finish ។




នៅពេលដែលអ្នកធ្វើការបើកនូវ Windows របស់អ្នក នោះកម្មវិធីនេះនឹងបង្ហាញនៅក្នុង “Startup” Directory ជាក់ជាមិនខាន។



បងជឿជាក់ថា ប្រសិនបើប្អូនធ្វើដូចជំហានដែលបងបានបង្ហាញនៅខាងលើនេះ ប្អូនប្រាកដជាទទួលបានផល 100% ហើយប្អូនអាចធ្វើការជ្រើសរើសនូវកម្មវិធីណាក៏បានដែលប្អូនពេញចិត្តសម្រាប់យកមកដាក់នៅក្នុង Startup Directory នេះ ៕

**ឈ្មោះ: សុខ ចាន់និមល**
Email: nimolsok@gmail.com

**សំនួរ៖** ជម្រាបសួរ! នាងខ្ញុំឈ្មោះ **សុខ ចាន់និមល** ជាប្រិយមិត្តអ្នកអានរបស់ទស្សនាវដ្តីទីក្រុងពត៌មានវិទ្យា និងទីក្រុងទូរស័ព្ទ ហើយរាល់ថ្ងៃខ្ញុំកំពុងសិក្សានៅសាកលវិទ្យាល័យផ្នែកពត៌មានវិទ្យា នៅក្នុងខេត្តបាត់ដំបង ឆ្នាំទី ១ ។ នៅពេលនេះប្អូនមានចម្ងល់មួយចង់សួរខាងបងឲ្យជួយបកស្រាយ។ រាល់ថ្ងៃប្អូនប្រើប្រាស់នូវ Web Browsers ដែលញឹកញាប់ជាងគេគឺ Chrome និង Firefox ប៉ុន្តែនៅលើ Chromes ប្អូនអាចបង្កើតនូវ Multiple Profiles បានយ៉ាងងាយស្រួល ប៉ុន្តែនៅលើ Firefox វិញ ប្អូនមិនអាចធ្វើបាននោះទេ។ តើធ្វើដូចម្តេចទើបអាចការ Set Up នូវ Multiple Profiles នៅលើ Firefox បាន? សូមបងជួយបង្ហាញដល់ប្អូនដោយអនុគ្រោះ និងសូមអរគុណចំពោះការចែករំលែកនេះ។

**ចម្លើយ៖** សួស្តីប្អូន **សុខ ចាន់និមល**! ជាបឋមទស្សនាវដ្តីទីក្រុងពត៌មានវិទ្យា និងទីក្រុងទូរស័ព្ទ សូមអរគុណដល់ប្អូនក៏ដូចជាប្រិយមិត្តអ្នកអានផ្សេងទៀតដែលតែងតែគាំទ្រទស្សនាវដ្តីរបស់យើងកន្លងមកនេះ ហើយក៏សូមអរគុណជាខ្លាំងចំពោះសំនួរប្អូនដែលបានសួរមកខាងបងដែលសំនួរនេះគឺពិតជាសំនួរដ៏ល្អ។ ដូច្នេះដើម្បីធ្វើការដោះស្រាយនូវបញ្ហាដែលប្អូនបានជួបប្រទះ ដូចនេះយើងខ្ញុំដែលជាក្រុមការងារក្នុងទស្សនាវដ្តីទីក្រុងពត៌មានវិទ្យានិងទីក្រុងទូរស័ព្ទសូមធ្វើការបង្ហាញដូចខាងក្រោមអំពីវិធីសាស្ត្រក្នុងការ Set Up នូវ Multiple Profiles នៅលើ Firefox នោះ៖

ជាការពិតណាស់ ការប្រើប្រាស់នូវ Multiple Profiles ដែលមនុស្សភាគច្រើនប្រើប្រាស់នៅលើ Chrome នោះដែលផ្តល់នូវភាពងាយស្រួលក្នុងការប្រើប្រាស់ទៅលើ Add-ons និងមុខងារជាច្រើនទៀតនៅលើ Websites នោះគឺមានភាពខុសគ្នាពីការដាក់វានៅលើ Firefox។

កម្មវិធី Mozilla Firefox បានធ្វើការលាក់ Profile Manager របស់វាដែលមិនបង្ហាញតែម្តងនៅលើ Browser ដូច Chrome នោះទេ។ ដំបូងអ្នកត្រូវធ្វើការបិទនូវកម្មវិធី Firefox ជាមុនសិនបន្ទាប់មកអ្នកត្រូវចុច Windows Key + R រួចវាយពាក្យថា firefox.exe –p បន្ទាប់មកចុច Enter ។




